ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jul-2015, 11:35
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៨នាទី**

**សវនាការលើកទី៣០៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង
លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា
លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន
លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី គួច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី កង អ៊ុត (2-TCW-855) | ខ្មែរ |

# ខ្ទបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី កខ អ៊ុត** (2-TCW-855)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ២
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី ........................................ ទំព័រ ៥
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........................................ ទំព័រ ២៤
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........................................ ទំព័រ ៣១
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្ដើមពី ........................................ ទំព័រ ៣៣
សួរដោយលោក លីវ សុវណ្ណា ផ្ដើមពី ........................................ ទំព័រ ៤១
សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី ........................................ ទំព័រ ៤៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-855 ដែលទាក់ទងនឹងអង្គហេតុទំនប់ ១មករា។

ក្រឡាបញ្ជីសវនាការ កញ្ញា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះ កោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCW-855 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីព្រឹកមិញនេះ។ សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំៗ ការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០១:១១]

**ប្រធានអង្គជំនុំ៖**

អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជន

ជាប់ចោទ នួន ជា ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិ និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃ២៥ ខែមិថុនា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ នួន ជា គឺមានអាការៈឈឺចង្កេះ វិលមុខពេលអង្គុយ ឈឺក្បាល ក្អកបន្តិចបន្តួច និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-855 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:០៤:១៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្ដីលោកស្រី តើលោកស្រីឈ្មោះអី?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៥១។

**ស៖** លោកស្រីកើតនៅទីណា?

ឈប់សិន! លោកស្រីកុំអាលទាន់ឆ្លើយចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយចេញភ្លើងក្រហមសិន។

**លោកស្រី កង អ៊ិត៖**

**ឆ៖** ខ្ញុំកើតនៅឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** លោកស្រីប្រកបមុខរបបអីដែរ?

**ឆ៖** ចាស នាងខ្ញុំមុខរបបធ្វើស្រែ។

**ស៖** ចុះទីលំនៅបច្ចុប្បន្នរបស់លោកស្រីនៅឯណាដែរ?

**ឆ៖** បច្ចុប្បន្នខ្ញុំនៅឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដដែល។

**ស៖** ប្ដីលោកស្រីឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីនាងខ្ញុំឈ្មោះ សែម រី។ មាន -- ខ្ញុំមានកូនពីរនាក់

**ស៖** ចុះ ឪពុកម្ដាយ? ឪពុកម្ដាយលោកស្រីមានឈ្មោះអីដែរ?

**ឆ៖** ឪពុកខ្ញុំឈ្មោះ កង ចក។ ម្ដាយឈ្មោះ អឹម ចាត។

**ស៖** អរគុណលោកស្រី កង អ៊ិត។ តាមរបាយការណ៍ក្រឡាបញ្ជីកាលពីព្រឹកមិញ បានបញ្ជាក់ថាតាមសមត្ថភាព និងលទ្ធភាពដែលលោកស្រីអាចដឹង លោកស្រីមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នោះទេ។ ពិតមែនអ៊ីចឹងទេ?

**ឆ៖** ចាស ពិតមែន។

[០៩:០៨:២៨]

**ស៖** ចា លោកស្រីបានស្បថ រួចហើយនៅចំពោះមុខលោកតាដំបងដែក មុនហ្នឹងចូលនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ ពិតមែនទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** អរគុណលោកស្រី។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកស្រីក្នុងឋានៈលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោកស្រី កង អ៊ិត ក្នុងឋានៈលោកស្រីជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបនឹងសំណួរ។ ឬការដែលលោកស្រីធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងហ្នឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកស្រីជាសាក្សី ត្រូវតែ

ឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតបរបស់លោកស្រី ឬការធ្វើអត្ថាធិប្បាយរបស់លោកស្រី នាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់លោកស្រីហើយអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សី លោកស្រីត្រូវតែឆ្លើយឱ្យការណ៍ តែការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុ-ការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោកស្រី។

លោកស្រី កង អ៊ុត តើលោកស្រីដែលផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើបានធ្វើ តើធ្វើប៉ុន្មានដង? ធ្វើនៅពេលណា? នៅទីកន្លែងណា?

**ឆ៖** ចាស ខ្ញុំធ្លាប់បានធ្វើម្ដងនៅផ្ទះមេឃុំ។

[០៩:១១:០០]

**ស៖** បាទ អរគុណ។ នៅពេលចូលចំពោះមុខអង្គជំនុំជម្រះនេះ តើលោកស្រីបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកស្រីបានផ្ដល់ចម្លើយកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំនោះដែរឬទេ?

**ឆ៖** ចាស ខ្ញុំមើលហើយ តែមិនចាំ។

**ស៖** ហើយតាមសម្ថភាពដែលលោកស្រីអាចចាំបាន តើលោកស្រីអាចបញ្ជាក់បានទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំ វាពិតជាត្រឹមត្រូវ វាស៊ីចង្វាក់គ្នាស្របនឹងចម្លើយលោកស្រីដែលបានផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតពីមុននោះដែរឬទេ?

**ឆ៖** ខ្ញុំមើលហើយ តែមិនចាំ ភ្លេចអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី កង អ៊ុត មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលកន្លះក្នុងការសាកសួរសាក្សីរូបនេះ។

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ជម្រាបសួរសាធារណជន។

[០៩:១៣:១៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី កង អ៊ុត ខ្ញុំឈ្មោះ វ៉ាំងសង់ ដេវីល ខ្ញុំចាប់ផ្ដើមសួរសំណួរទៅលោកស្រី។ តំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា ហើយសហការីខ្ញុំក៏នឹងមានសំណួរមួយចំនួនផងដែរ។ សូមលោកស្រីស្ដាប់សំណួរឲ្យបានច្បាស់ គឺយើងនឹងសួរពាក់ព័ន្ធទៅនឹងខែមេសា ឆ្នាំ៧៥ រហូតទៅដល់ដើមខែមករា ឆ្នាំ១៩៧៩។ សូមឲ្យលោកស្រីឆ្លើយឲ្យបានច្បាស់ៗខ្លីទៅនឹងសំណួររបស់ខ្ញុំ។

នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រីគឺ D166/18 លោកស្រីថាលោកស្រីកើតនិងរស់នៅភូមិត្រស់ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ តើលោកស្រីអាចជម្រាបបានទេ ថានៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ គឺលោកស្រីនៅក្នុងកងចល័តមួយដែលមានសុទ្ធតែអ្នកធ្វើការ មានអាយុប្រហាក់ប្រហែលនឹងលោកស្រីនៅក្នុងភូមិត្រស់ ជាអ្នកមកពីភូមិត្រស់?

**លោកស្រី កង អ៊ុត៖**

**ឆ៖** កាលឆ្នាំ១៩៧៥ និង១៩៧៧ នាងខ្ញុំធ្វើការ ធ្វើកងចល័ត គេឲ្យធ្វើកងចល័ត។

**ស៖** តើអ្នកណាជាមេក្រុម ឬក៏ជាមេកងចល័តរបស់លោកស្រីនៅក្នុងអំឡុងពេលនោះ?

**ឆ៖** មេកងចល័តឈ្មោះ -- កងចល័តឈ្មោះ មិត្តងឹម ជានារី នៅខាងភូមិឈូកខ្សាច់ តែឥឡូវនេះមិនដឹងជាទៅឯណាទេ។

**ស៖** គាត់ជាមេផ្ទាល់របស់លោកស្រី ឬក៏ជាមេកងចល័តទាំងមូលតែម្ដង?

**ឆ៖** គាត់ជាកងចល័តសម្រាប់ធ្វើការងារក្នុងការដ្ឋាន។

**ស៖** បាទ សូមអរគុណ។ ចុះអ្នកណាជាមេផ្ទាល់របស់លោកស្រី? តើមានអ្នកណាម្នាក់ផ្សេងទៀតដែលដឹកនាំរបស់ -- ដឹកនាំលោកស្រីធ្វើការ ហើយស្ថិតនៅក្រោមបញ្ជារបស់ ងឹម?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ អត់ចាំទេ ភ្លេចហើយ ភ្លេចឈ្មោះអស់ហើយ។

[០៩:១៦:៤៤]

**ស៖** តើអ្នកមកពីឃុំបល្ល័ង្គដែលធ្វើការនៅកងចល័តរបស់លោកស្រីហ្នឹងមានគ្នាច្រើនទេលោកស្រីដឹងពីចំនួនប្រហាក់ប្រហែលទេ?

**ឆ៖** កងចល័តនៅខាងភូមិខ្ញុំហ្នឹង គឺតាមភូមិទេតែក្នុងមួយក្រុមៗមានចំនួនជាង១០នាក់ទេ។

**ស៖** នៅក្នុងកំណត់ហេតុរបស់លោកស្រីគឺនៅទំព័រ២ ក្នុងភាសាទាំងបី លោកស្រីបាននិយាយថា៖ "លោកស្រីបានចូលរួមធ្វើការសាងសង់ទំនប់១មករា គឺនៅដើមឆ្នាំ១៩៧៧"។ នៅពេលដែលលោកស្រីធ្វើការនៅការដ្ឋានហ្នឹង គឺលោកស្រីនៅតែស្ថិតនៅក្នុងកងចល័តភូមិត្រស់ហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំនៅក្នុងចល័តនៅភូមិត្រស់ហ្នឹង។

**ស៖** តើការសាងសង់ទំនប់១មករា នៅសម័យនោះគេហៅថាជាសមរភូមិក្តៅមែនទេ?

**ឆ៖** ចាស គេហៅសមរភូមិក្តៅ។

**ស៖** តើលោកស្រីដឹងទេថា ហេតុអីបានជាគេហៅកន្លែងនុំងថាជាសមរភូមិក្តៅ?

**ឆ៖** ព្រោះធ្វើការយ៉ាប់យឺន ហួសកម្លាំងពេក។

**ស៖** នៅការដ្ឋាននោះ តើលោកស្រីដឹងទេថា ការសាងសង់ហ្នឹងគឺជាទំនប់ដ៏សំខាន់មួយនៅក្នុងភូមិភាគឧត្តរ ឬក៏យើងហៅថាជាភូមិភាគកណ្តាលនោះ?

**ឆ៖** ចាស ខ្ញុំមិនដឹងដែរ មិនសូវដឹងទេ។ ដឹងតែធ្វើ គេឲ្យធ្វើ ចេះតែធ្វើទៅ។

[០៩:១៩:២៣]

**ស៖** លោកនិយាយអំពីការធ្វើការខ្លាំង។ តើអ៊ីចឹងគេមានបង្គំឲ្យកម្មករធ្វើការសាងសង់អាងទំនប់ ហើយនិងទំនប់ហ្នឹងឲ្យបានឆាប់រហ័សទេ?

**ឆ៖** គេឲ្យធ្វើ គេឲ្យប្រឹងធ្វើអត់មានម៉ោងសម្រាកយូរទេ ដើម្បីឲ្យឆាប់រហ័សរួច។

**ស៖** តើលោកស្រីចាំទេ នៅពេលនោះ អ្នកណាជាប្រធានភូមិភាគរបស់លោកស្រី ហើយតើប្រធានភូមិភាគនេះ មានមកពិនិត្យមើលដំណើរការសាងសង់ហ្នឹង ថាវិវត្តន៍ទៅដល់ណាៗទេ?

**ឆ៖** ចាស ខ្ញុំមិនស្គាល់ទេ។ មិនដែលឃើញទេ តែឮថា បើគេថា បើគេមកមើល គេឲ្យយើងប្រឹងធ្វើការឲ្យបានខ្លាំង។

**ស៖** តើគេបញ្ជាឲ្យលោកស្រីធ្វើការឲ្យបានខ្លាំងហ្នឹង ញឹកញាប់ទេ?

**ឆ៖** ចាស គេឲ្យយើងធ្វើតាំងពីព្រឹកម៉ោងបួនទៅរហូតដល់ម៉ោងប្រាំពីរព្រឹក ឈប់១៥នាទីហើយដល់ម៉ោងដប់មួយបានគេឲ្យហូបបាយ។ គេឲ្យហូបបាយម៉ោងដប់មួយរួច សម្រាកបន្តិចម៉ោង

មួយចាប់ផ្ដើមធ្វើទៀតរហូតទល់ម៉ោងប្រាំ ហើយហួសដល់ម៉ោងប្រាំរហូតដល់ម៉ោងប្រាំពីរយប់គេឲ្យមកធ្វើការទៀត រហូតទល់ម៉ោងដប់យប់ ទើបសម្រាក។ ហើយបើមានប្រជុំ គឺរហូតដល់ទៅម៉ោងដប់ពីរយប់អធ្រាត្រ។

[០៩:២២:០៩]

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយអំពីពេលម៉ោងធ្វើការនៅពេលបន្តិចទៀត។ ក៏ប៉ុន្តែលោកស្រីបាននិយាយថា ពេលដែលប្រធានភូមិភាគមកមើលហ្នឹង គេឲ្យធ្វើការឲ្យកាន់តែខ្លាំង។ អ៊ីចឹងនៅពេលដែលមានថ្នាក់ដឹកនាំមកទស្សនកិច្ចហ្នឹង តើគេមានប្រាប់ឲ្យលោកស្រីធ្វើការដូចជា រែកដីអីឲ្យរត់ទេ?

**ឆៈ** ចាស ដល់គេមកមើលអ៊ីចឹង គេប្រាប់យើង ប្រធានក្រុមគេប្រាប់យើងថា លោកធំមកហើយឲ្យធ្វើការឲ្យខ្លាំង ឲ្យរែករត់ គឺនាងខ្ញុំទាំងអស់គ្នាក៏ខំរែករត់ទៅ។

**សៈ** លោកស្រីបាននិយាយអំពីពេលម៉ោងធ្វើការ អ៊ីចឹងខ្ញុំចង់ដឹងថា តើពេលម៉ោងធ្វើការនេះ គឺគេកំណត់បែបហ្នឹង ដើម្បីឲ្យធ្វើការសាងសង់ទំនប់នោះ ឲ្យបានឆាប់រហ័សក្នុងរយៈពេលកំណត់ណាមួយតាមដែលគេចាត់តាំង។ តើអ៊ីចឹងមែនទេ?

**ឆៈ** ចាស អ៊ីចឹងមែនហើយ គេប្រញាប់ឲ្យឆាប់រួច។

**សៈ** លោកបាន -- លោកស្រីបាននិយាយថា ការសាងសង់ហ្នឹងចាប់ផ្ដើមនៅឆ្នាំ១៩៧៧។ តើលោកស្រីចាំថានៅខែណាទេ ពេលចាប់ផ្ដើមធ្វើការដំបូងហ្នឹង បើមិនចាំខែទេ អាចចាំថាជារដូវប្រាំងឬក៏ជារដូវវស្សាអីទេ?

[០៩:២៣:៥២]

**ឆៈ** រដូវប្រាំង។ ខ្ញុំមិនសូវចាំខែដែរ ប៉ុន្តែធ្វើហ្នឹងរដូវប្រាំង។

**សៈ** លោកស្រីធ្វើការនៅទំនប់ហ្នឹងយូរទេ? បើគិតទៅប្រហែលជាប៉ុន្មានខែដែរ?

**ឆៈ** ខ្ញុំភ្លេចអស់ហើយ ប្រហែលជាបួនខែជាងទំនប់ហ្នឹង។ បួនប្រាំមើលទៅ ខ្ញុំមិនសូវចាំដែរ។

**សៈ** ចុះក្រោយមកទៀត គេមានបញ្ជូនលោកស្រីទៅធ្វើការនៅទំនប់ ៦មករា ទេ ដែលនៅជាប់នឹងទំនប់ ១មករា ដែរហ្នឹងនោះ?

**ឆៈ** នៅពេលទំនប់ ១មករា ហ្នឹង ខ្ញុំរៀបគ្រួសារហើយ គេអត់ឲ្យទៅធ្វើទេ។ គេឲ្យទៅធ្វើតាមមុខព្រួញផ្សេងៗ ដូចជាលើកភ្លឺស្រែអ៊ីចឹងទៅ ស្ទូងដកអ៊ីចឹង។

**សៈ** នៅពេលដែលលោកស្រីទៅដល់ភ្លាមជាមួយក្រុមការងាររបស់លោកស្រីហ្នឹង គេចាប់

ផ្ដើមធ្វើហើយ ឬក៏លោកស្រីទៅដល់ហ្នឹង គឺមិនទាន់ទេ គឺលោកស្រីជាក្រុមដំបូងគេ ដែលទៅដល់ចាប់ផ្ដើមការងារភ្លាមនោះ?

**ឆ៖** ចាស ទៅហ្នឹង ទៅទាំងអស់គ្នា ទៅទាន់ៗគ្នា ធ្វើទាំងអស់គ្នាតែម្ដង មិនមានអ្នកណានៅក្រោយទេ គេកំណត់ម៉ោង។

**ស៖** នៅពេលដែលលោកស្រីចាប់ផ្ដើមធ្វើដំបូងនោះ តើលោកស្រីមានបានចូលរួមពិធីសម្ពោធបើកការដ្ឋានសាងសង់ទំនប់១មករា ហ្នឹងទេ?

**ឆ៖** ចាស នាងខ្ញុំមិនដែលបានទៅទេ។ ទៅៗ តែប្រធានក្រុមហ្នឹង គេទៅៗ។

[០៩:២៦:៤៣]

**ស៖** បាទ សូមអរគុណ។ ចុះពេលធ្វើការ ដែលលោកស្រីថាចាប់ផ្ដើមនៅរដូវប្រាំងហ្នឹង លោកស្រីមានធ្វើបន្តរហូត ទៅដល់ចូលទៅដល់រដូវវស្សាទេ?

**ឆ៖** ចាស អត់ទេ ខ្ញុំធ្វើតែខែប្រាំង ហើយខ្ញុំគេឲ្យទៅមុខព្រួញផ្សេង។

**ស៖** តើលោកស្រីស្គាល់ស្ត្រីម្នាក់ដែលមកពីភូមិត្រស់ គាត់មកផ្ដល់សក្ខីកម្មនៅទីនេះ គាត់ឈ្មោះ មាស ឡៃហួរ ប្រហែលជាសម័យនោះគេហៅគាត់ថា ហួរ។ លោកស្រីស្គាល់គាត់ទេ មាស ឡៃហួរ?

**ឆ៖** នៅភូមិត្រស់ ចាស ស្គាល់។

**ស៖** ដើម្បីឲ្យលោកស្រីស្គាល់ច្បាស់ គឺថាគាត់រៀបការជាមួយនឹងបុរសមួយរូបឈ្មោះ ភុក សុជន តើលោកស្រីដឹងច្បាស់ថា ពិតជាគាត់ហ្នឹងហើយមែនទេ មាស ឡៃហួរ ហ្នឹង?

**ឆ៖** ចាស គាត់ហ្នឹងហើយ ប្ដីឈ្មោះ ជន។

**ស៖** តើ មាស ឡៃហួរ នេះគាត់ធ្វើការជាមួយលោកស្រីនៅទំនប់ហ្នឹងមែនទេ ហើយគាត់ធ្វើការនៅក្នុងក្រុមតែមួយ ឬក៏កងតែមួយជាមួយលោកស្រីមែនទេ?

**ឆ៖** គាត់ធ្វើនៅហ្នឹងជាមួយដែរ ប៉ុន្តែខ្ញុំភ្លេចក្រុម គាត់មិនដឹងក្រុមណា ខ្ញុំភ្លេចហើយ យូរពេក។

**ស៖** អ៊ីចឹងនៅក្នុងភូមិត្រស់ នោះមានច្រើនក្រុមមែនទេ លោកស្រីនិយាយថាមានមួយក្រុម ១០នាក់ អ៊ីចឹងក្នុងភូមិលោកស្រីហ្នឹង គឺមានក្រុមលើសពីលើសមួយមែនទេ មានន័យថាមានច្រើនក្រុមផ្សេងគ្នា?

[០៩:២៨:០២]

**ឆ៖** ចាស មានក្រុមផ្សេងគ្នា តែខ្ញុំភ្លេចក្រុមអស់ហើយ មិនដឹងប៉ុន្មានក្រុមទេ ភ្លេចអស់ហើយ យូរមកហើយ ខ្ញុំមិនចាំ។

**ស៖** ចំពោះចំនួនអ្នកធ្វើការនៅការដ្ឋាន លោកស្រីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅក្នុងកំណត់ហេតុ D166/38 នៅទំព័រជាភាសាបារាំង គឺ២-៣, ជាភាសាអង់គ្លេស ទំព័រ២ ហើយជាភាសាខ្មែរ ទំព័រ៣ លោកស្រីថា៖ "មានមនុស្សរាប់ម៉ឺននាក់បានចូលរួមធ្វើការនៅទីនោះ ពួកគេមកពីកំពង់ស្ពឺ និងកំពង់ចាម ភាគច្រើនជាយុវជន និងយុវនារីដែលមកពីកងចល័ត"។ សូមបញ្ចប់ការដកស្រង់។ ក្រៅពីអ្នកមកពីកំពង់ចាម កំពង់ស្ពឺ លោកស្រីផ្ទាល់មកពីកំពង់ធំ។ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកធ្វើការនៅការដ្ឋានហ្នឹង មានគ្នាច្រើនទេដែលមកពីកំពង់ធំនោះ?

**ឆ៖** ចាស នៅក្នុងទំនប់ហ្នឹង មានច្រើនប្រហែលរាប់ម៉ឺននាក់ មកធ្វើនៅទំនប់ហ្នឹង ពីខេត្តកំពង់ចាម កំពង់ធំ។

**ស៖** អ្នកដែលធ្វើការនៅទីនោះ គឺមកពីតំបន់បីនៃអតីត -- នៃភូមិភាគឧត្តរចាស់ មែនទេ? ហើយខ្ញុំចង់ដឹងថា តើមានអ្នកណាដែលមកពីខេត្តក្រចេះទេ?

**ឆ៖** ពីខេត្តក្រចេះខ្ញុំដូចជា មិនដឹង -- ដឹងច្រើនតែត្រឹមខេត្តកំពង់ចាម។

**ស៖** តើហេតុអ្វីបានជាគេជ្រើសរើសលោកស្រី យកទៅធ្វើការនៅការដ្ឋាន១មករា? តើគេមានគិតលើអាយុ ឬក៏កម្លាំងកាយយ៉ាងម៉េចទេ ដើម្បីយកទៅធ្វើការនៅការដ្ឋាននោះ?

**ឆ៖** និយាយទៅឲ្យគេ ឲ្យតែនារីលីវ គេយកដាក់ធ្វើកងចល័ត ដើរធ្វើការ ធ្វើការខ្លាំង។

[០៩:៣២:១០]

**ស៖** ចុះនៅកន្លែងហ្នឹងមានក្មេងៗធ្វើការទេ? ហើយលោកស្រីអាចជម្រាបបានទេ ថាអ្នកដែលក្មេងជាងគេបំផុតនៅការដ្ឋានហ្នឹងមានអាយុប៉ុន្មានដែរ?

**ឆ៖** ចាស អត់មានទេ ក្មេងធ្វើការអត់មានទេ។ មានតែត្រឹមអាយុ២០ អាយុ១៨ ម្ភៃលើស។

**ស៖** ក្នុងចំណោមអ្នកធ្វើការមកពីកំពង់ធំ និងកំពង់ចាម តើមនុស្សភាគច្រើនជាអ្នកចាស់មែនទេ? ហើយក្នុងចំណោមអ្នកទាំងអស់ហ្នឹង មានអ្នកថ្មីទេ?

**ឆ៖** មានចាសច្រើនអាយុជាង២០, ២៥, ២៣ អីហើយ ភាគច្រើនសម្បូរអ្នកថ្មី មានសម្បូរប្រជាជនថ្មី។

**ស៖** ចុះជនជាតិចាមមានធ្វើការនៅការដ្ឋានហ្នឹងទេ?

**ឆ៖** ចាសមានៗធ្វើដែរ ធ្វើ -- មួយៗជាប្រជាជនចាមមកនៅតាមភូមិទៅ ៗធ្វើជាមួយទៅ ក៏ផ្ញៀតធ្វើដាក់ជាកងចល័តដែរ។

**ស៖** នៅពេលដែលលោកស្រីនិយាយថា ពួកចាមរស់នៅក្នុងភូមិហ្នឹង មានន័យថាពួកគាត់រស់នៅក្នុងភូមិហ្នឹងតាំងពីយូរយារណាស់មកហើយ ឬក៏គេទើបតែជម្លៀសពួកគាត់មកកាន់ភូមិហ្នឹងទេ

**ឆ៖** ចាសគេទើបតែជម្លៀសមកទេ គាត់នៅជាមួយហ្នឹង ហើយក៏គេដាក់ទៅក្នុងកងចល័តជួយធ្វើការទៅ។

[០៩:៣៤:២៣]

**ស៖** អម្បាញ់មិញនេះ លោកស្រីមិនអាចប្រាប់ឈ្មោះមេក្រុមរបស់លោកស្រីបានទេ។ ក៏ប៉ុន្តែនៅក្នុងកំណត់ហេតុរបស់លោកស្រីហ្នឹង លោកស្រីបានប្រាប់ថាឈ្មោះ យឿង ជាប្រធានរបស់លោកស្រី គឺនៅទំព័រទី៤ ជាភាសាបារាំង, ៣ ជាភាសាអង់គ្លេស, ៤ ជាភាសាខ្មែរ។ តើលោកស្រីអាចបញ្ជាក់ម្តងទៀតទេ បានម្តងទៀតទេថា ឈ្មោះ យឿង នេះមែនទេ ដែលជាប្រធានក្រុមរបស់លោកស្រីនោះ?

**ឆ៖** ចាស ឈ្មោះ យឿង ហ្នឹងជាប្រធានក្រុម។ ក្រុមក្តាប់ត្រឹម១២នាក់ ១០នាក់។ នៅសព្វថ្ងៃនៅរស់ទេ នៅទេ។

**ស៖** តើមានមេក្រុមណាមួយទៀត ឈ្មោះ នារីម៉ុ ទេ?

**ឆ៖** អត់មានទេ។ នារីម៉ុ ហ្នឹងមាន តែស្លាប់អស់ហើយ។ ប៉ុនខាងក្រុម ខាងកងៗគេផ្សេងទេ។

**ស៖** លោកស្រីចាំទេថាគាត់មានមុខងារអ្វីដែរ ដែលលោកស្រីថា គាត់នៅក្នុងកងផ្សេងហ្នឹង នារីម៉ុ ហ្នឹង?

**ឆ៖** គាត់អត់ធ្វើការអ្វីផង។ តែគាត់ស្លាប់បាត់ហើយ។

**ស៖** អម្បាញ់មិញនេះលោកស្រីនិយាយថា លោកស្រីចាប់ផ្តើមធ្វើការតាំងពីម៉ោងបួនព្រឹក។ ដូច្នេះខ្ញុំចង់ដឹងថា ម៉ោងបួននេះ គឺជាម៉ោងបួនដែលលោកស្រីចាប់ផ្តើមធ្វើការតែម្តង ឬក៏ជាម៉ោងដែលលោកស្រីភ្ញាក់ពីគេងទេ?

**ឆ៖** ម៉ោងបួនហ្នឹង គឺម៉ោងចេញទៅធ្វើការតែម្តង។

**ស៖** អ៊ីចឹងលោកស្រីងើបម៉ោងប៉ុន្មានដែរ នៅសម័យនោះ?

**ឆ៖** ងើបមុនម៉ោងបួន។ ទម្រាំស្លៀកពាក់អីរួច ម៉ោងបួនចេញទៅតែម្តង។ ភ្ញាក់ឡើងគេផ្លុំកញ្ចែតម្រង់ជួរ។ ម៉ោងបួនតម្រង់ជួរចេញ។

[០៩:៣៧:៤២]

**ស៖** លោកស្រីធ្វើការនៅទីនោះ អស់ជាច្រើនខែ។ ដូច្នេះ ខ្ញុំចង់ដឹងថា ពីកន្លែងដែលលោកស្រីធ្វើការ -- ពីកន្លែងលោកស្រីសម្រាក និងកន្លែងលោកស្រីធ្វើការហ្នឹងមានចម្ងាយពីគ្នាប៉ុន្មានដែរ? ហើយកន្លែងសម្រាកហ្នឹង គេមានផ្លាស់ប្ដូរទេ? គេមានលើកទៅសង់នៅកន្លែងណាផ្សេងទៀតទេ?

**ឆ៖** កន្លែងសម្រាកហ្នឹង ឆ្ងាយពីកន្លែងធ្វើការប្រហែលជា ៥០០ម៉ែត្រដែរ តែគេមិនដែលផ្លាស់ប្ដូរទៅណាទេ កន្លែងត្រង់ណានៅត្រង់ហ្នឹង នៅដដែល។

**ស៖** នៅក្នុងកំណត់របស់លោកស្រី ហើយអម្បាញ់មិញក៏អ៊ីចឹងដែរ លោកស្រីថា លោកស្រីធ្វើការពេលយប់គឺពីម៉ោងប្រាំពីរយប់រហូតទៅដល់ម៉ោងដប់យប់។ ហើយជួនកាលទៅមានប្រជុំទៀត គឺរហូតទៅដល់ម៉ោងដប់ពីរកណ្ដាលអធ្រាត្រឯណោះ ទើបអាចបានចូលសម្រាក។ គឺនៅទំព័រ៣ ជាភាសាបារាំង, ២-៣ ជាភាសាអង់គ្លេស និងទំព័រទី៣ ជាភាសាបារាំង។ តើគេមានប្រាប់មូលហេតុអីទេថាដែលលោកស្រីត្រូវតែធ្វើការបាន -- ឲ្យបានច្រើន ហើយសម្រាកឲ្យបានតិចៗម៉ោងបែបនេះនោះ?

**ឆ៖** គេមិនដែលប្រាប់អីទេ អត់មានប្រាប់ ដឹងតែប្រឹងធ្វើហ្នឹង។

**ស៖** លោកស្រីនិយាយពីការប្រជុំ។ អ៊ីចឹងខ្ញុំចឹងដឹងថា ការប្រជុំហ្នឹង ជាប្រជុំបែបណាដែរ? ជាប្រជុំពេលយប់ហ្នឹង ប្រជុំទិតៀន ស្វ័យទិតៀន ឬក៏ប្រជុំអីផ្សេង?

**ឆ៖** ចាស គេប្រជុំឲ្យប្រឹងធ្វើការ ហើយគេទិតៀនយើងឲ្យ ឲ្យយើងឆាប់ក្រោកពីសម្រាកទៅឲ្យទាន់ពេលម៉ោងអ៊ីចឹង។ គេពង្រឹង។

**ស៖** ចំពោះការងារពេលយប់ហ្នឹង តើមានអ្នកណាដែលមានបញ្ហាភ្នែក ដូចជាខ្វាក់មាន់ ដែលគេតម្រូវឲ្យធ្វើការនៅពេលយប់ទេ?

**ឆ៖** គ្មានទេ អត់មានទេ បើមាន១ថាចុងភៅ១មានខ្វាក់មាន់។ ឯចុងភៅដាំស្លរួច គេឲ្យមកផ្ទះ ហើយ ខ្វាក់មាន់ដើរមកធ្លាក់គ្រហុក ធ្លាក់អី គ្នាពោះធំផង។

[០៩:៤១:១៩]

**ស៖** លោកស្រីនិយាយអំពីហេតុការណ៍នៅក្នុងកងរបស់លោកស្រី ឬក៏យ៉ាងម៉េច? ខ្ញុំដឹងថាលោកស្រីមិនដឹងអំពីរឿងរ៉ាវនៅក្នុងកងផ្សេងទៀតទេ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថានៅក្នុងកងរបស់លោកស្រីហ្នឹង គឺអត់មានអ្នកណាកើតជំងឺខ្វាក់មាន់ទេ មែនទេ?

**ឆ៖** ចាសអត់មានទេ។

**ស៖** តើលោកស្រីអាចជម្រាបបានទេ ថាការងារប្រចាំថ្ងៃនៅទំនប់ហ្នឹង លោកស្រីធ្វើអ្វីខ្លះចាប់ពីម៉ោងបួនព្រឹកហ្នឹងរហូតទៅដល់យប់ហ្នឹង?

**ឆ៖** ចាស នាងខ្ញុំរែកដី ចាប់ពីម៉ោងបួនរហូតម៉ោងប្រាំពីរព្រឹក រហូតទៅម៉ោងប្រាំពីរព្រឹកសម្រាក១៥នាទី រហូតម៉ោងដប់មួយបានឈប់សម្រាកហូបបាយ។

**ស៖** សំណួរដែលខ្ញុំសួរហ្នឹង ខ្ញុំចង់ដងថាលោកស្រីធ្វើការប្រភេទណាខ្លះ ឧទាហរណ៍ដូចជាជីកដី រែកដី ឬក៏លាយស៊ីម៉ង់ត៍ ចាក់ស៊ីម៉ង់ត៍ ដើម្បីសង់ទំនប់ហ្នឹង។ ខ្ញុំចង់ងដឹងថាការងារប្រភេទណាដែលលោកស្រីធ្វើក្នុងចំណោមការងារដែលខ្ញុំរៀបរាប់ហ្នឹង?

**ឆ៖** ខ្ញុំធ្វើតែរែកដីទេ បើថាវាជីកអីកាប់អីយុវជនទាំងអស់។ គឺនារីរែកៗរហូត។

**ស៖** តើគេមានកំណត់ផែនការឲ្យរែកក្នុង១ថ្ងៃប៉ុន្មានទេ? គេមានកំណត់ថាម្នាក់ក្នុង១ថ្ងៃត្រូវរែកប៉ុន្មានគូបៗទេ?

**ឆ៖** កំណត់ទេ គេវាស់ដីឲ្យជីក តែខ្ញុំភ្លេចហើយ មិនដឹងប៉ុន្មានទេ ភ្លេចអស់ហើយ។ គេគិតតែវាស់ដីចែក។

**ស៖** តើផែនការហ្នឹងដូចគ្នាក្នុងរយៈពេលដែលលោកស្រីធ្វើការនៅទីនោះររហូត ឬក៏ប្រែប្រួលទៅតាមប្រភេទដី។ តើលោកស្រីអាចដឹង អាចចាំបានដែរឬទេថាលោកស្រីត្រូវរែកចំនួនប៉ុន្មានម៉ែត្រគូបក្នុង១ថ្ងៃ?

[០៩:៤៤:១៩]

**ឆ៖** ដាក់កំណត់ទេ គេវាស់ចែកមួយប្លង់ៗ រួចទៅគេរែកទៅទាំងយុវជនទាំងនារី។

**ស៖** ប៉ុន្តែលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ អំពីការលំបាករបស់លោកស្រីដែលជាអ្នករែកដីនោះ? ហើយនិងការឈឺចាប់ដែលនៅតែបន្តមកទៀត ក្រោយពីរែកដីហ្នឹង។ លោកស្រីអាចពិពណ៌នាជូនតុលាការស្តាប់បានទេថា តើលោកស្រីមានការលំបាកប៉ុនណា? ហើយការឈឺចាប់ដែលសល់នោះប៉ុនណាដែររហូតដល់ពេលនេះ?

**ឆ៖** ចាស នាងខ្ញុំឈឺចាប់ប្រើហួសកម្លាំងពេក រកអ្វីប្រៀបពុំបាន បាក់កម្លាំងរហូតទាល់តែសព្វថ្ងៃ។

**ស៖** តើលោកស្រីត្រូវរែកដីហ្នឹងចម្ងាយប៉ុន្មានម៉ែត្រដែរ បើធៀបពីកន្លែងដែលគេជីក ដែលគេកាប់ដីហ្នឹង ហើយដែលត្រូវលើកមកលើខ្នងទំនប់ហ្នឹង។ តើមានចម្ងាយប៉ុន្មានម៉ែត្រដែរលោកស្រី?

**ឆ៖** ចាស ចម្ងាយពីជម្រៅក្រោមមកប្រហែលជា៣០ម៉ែត្រ ៤០ម៉ែត្រមើលទៅ រែកឡើងទួល។

**ស៖** តើនៅឃុំបារាយណ៍ដែលលោកស្រីរែកដី ហើយនិងលើកទំនប់ហ្នឹង ឬក៏នៅឃុំណាផ្សេង កន្លែងណាផ្សេង?

**ឆ៖** រែកដីហ្នឹងនៅភូមិព្រៃស្រងែ ប៉ុន្តែសង្កាត់បល្ល័ង្គ។

**ស៖** តើនៅតំបន់ហ្នឹងមានថ្មច្រើនទេ នៅក្នុងដីដែលគេជីកនោះ គេកាប់នោះ ឬក៏ដីហ្នឹងជាដីទន់ទេ ផុយទេ ស្រួលកាប់ទេ?

**ឆ៖** នៅកន្លែងកាប់ហ្នឹងដីតែលើទេ ទៅក្រោមទៅសុទ្ធតែថ្ម ដាប់ គេដាប់យុវជនអ្នកដាប់ នារីរែក។

**ស៖** តើលោកស្រីមានបានឃើញ ឬក៏បានដឹងថាមានគ្រោះថ្នាក់នៅលើការដ្ឋានហ្នឹងដែរឬទេ ដោយសារមានថ្មរមៀលអីជាដើមនោះ បង្កឲ្យមានគ្រោះថ្នាក់?

**ឆ៖** ចាស ខ្ញុំដឹងថានៅខាងជិតស្ពាន គឺដាប់ថ្មទៅ បាក់ថ្មលើមានស្លាប់មនុស្ស។

[០៩:៤៩:០៨]

**ស៖** តើមានស្ពាន ឬក៏ទ្វារទឹកអីហ្នឹងដែលបាក់ហើយ ទឹកហ្នឹងក៏នាំយកទៅជាមួយអស់ទៅមាន ធ្លាប់មានករណីហ្នឹងកើតឡើងទេ?

**ឆ៖** ចាស អត់មានទេ អត់មានបាក់ទេ មានឮថាបាក់ថ្មលើមនុស្ស មាន។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមចូលនិយាយអំពីលក្ខខណ្ឌការងារ ហើយនិងជីវភាព និងរបបអាហារ។ លោកស្រីនិយាយដូច្នេះចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺឯកសារ D116/18 ទំព័រទី៣ ក្នុងភាសាទាំងបី។ គេសួរលោកស្រីថា "តើរបបអាហាររបស់លោកស្រីយ៉ាងម៉េចដែរ?" លោកស្រីឆ្លើយថា "គេឲ្យយើងហូបពីរដងមួយថ្ងៃ គឺម៉ោងដប់មួយម្ដង និងម៉ោងប្រាំសៀល -- ល្ងាចម្ដង។ មានម្ហូបតែដដែលទេ គឺជាទូទៅសម្លម្ជូរត្រីកញ្ចុះស្ លឹកអំពិល។" បាទ សូមបញ្ចប់ការដកស្រង់។ លោកស្រីមានរបបអាហារពីរដងក្នុងមួយថ្ងៃ គឺលើកទី១ ម៉ោងដប់មួយថ្ងៃត្រង់។ អ៊ីចឹងខ្ញុំសួរលោកស្រី ថាតើលោកស្រីស៊ូទ្រាំយ៉ាងម៉េចនឹងបាន បើចាប់ផ្ដើមធ្វើការតាំងពីម៉ោងបួនព្រឹក ហើយបញ្ចប់ទៅវិញនៅម៉ោងដប់ពីរកណ្ដាលអធ្រាត្រឯនោះ សួរថារបបអាហារប៉ុណ្ណឹងលោកស្រីស៊ូទ្រាំយ៉ាងម៉េចនឹងបាន?

**ឆ៖** ចាស នាងខ្ញុំចេះតែទ្រាំទៅ បើទាំងអស់គ្នា គេក៏អ៊ីចឹង យើងក៏អ៊ីចឹង ហើយទ្រាំ។ ទ្រាំទាំងហេវទាំងហត់ ឈឺចាប់ ចេះតែប្រឹងទៅ។

[០៩:៥១:៣៧]

**ស៖** តើធៀបនឹងរយៈពេលធ្វើការជាច្រើនម៉ោង ដែលត្រូវធ្វើក្រោមកម្ដៅថ្ងៃ តើម្ហូបអាហារដែលគេឲ្យនោះ គ្រប់គ្រាន់ដែរឬទេ ដើម្បីឲ្យលោកស្រីអាចបំពេញការងារលោកស្រីបាននោះ? ការហូបចុកនោះ ដែលគេឲ្យហ្នឹងគ្រប់ដែរឬទេ?

**ឆ៖** ចាស គ្រប់វាចេះតែហូបទៅ គ្រប់មិនគ្រប់ក៏ចេះតែប្រឹងហូបតិចទៅ ឆ្អែតមិនឆ្អែតក៏ឈប់ទៅ។ ឆ្អែតហើយ តែហូបវាមិនឆ្ងាញ់។

**ស៖** តើលោកស្រី ហើយនិងអ្នកធ្វើការជាមួយលោកស្រីនោះ ធ្លាប់លួចម្ហូបអាហារដែរឬទេ? ឬក៏លួចបេះផ្លែឈើ ឬក៏ចាប់កង្កែប ចាប់សត្វល្អិតអីមកហូបបង្គ្រប់ជាដើមនោះ តើលោកស្រីធ្លាប់ធ្វើអីចឹងទេ ក៏ដូចជាអ្នកធ្វើការជាមួយលោកស្រីដែរនោះ?

**ឆ៖** នាងខ្ញុំមិនដែលទេ បើក្រុមផ្សេង ខ្ញុំមិនដឹងដែរ។ បើខ្ញុំអត់ដែលទេ អត់ដែលធ្វើ អត់ដែលលួច។

**ស៖** តើអ្នកធ្វើការដែលឈឺធ្ងន់ នៅតែបន្តធ្វើការដដែលទេ ដោយសារគាត់ភ័យខ្លាចគេបង្អត់អាហារគាត់ ឬក៏តើធ្លាប់លោកស្រីធ្លាប់ជួបប្រទះទេ អ្នកដែលហេវហត់ ដែលមនុស្សទាំងអស់ហេវហត់ ហើយតែនៅតែបង្ខំធ្វើការព្រោះខ្លាចគេ -- ព្រោះថាគេបង្អត់អាហារដោយសារតែគាត់ធ្វើការអត់បានបំពេញផែនការឲ្យគេគ្រប់គ្រាន់ ធ្លាប់ជួបប្រទះទេ លោកស្រីធ្លាប់ជួបករណីហ្នឹងទេ?

[០៩:៥៤:០៩]

**ឆ៖** ខ្ញុំមិនដែលឃើញដែរ។ ឃើញតែបើគេឈឺ គេសម្រាកនៅនឹងរោង ហើយពេទ្យគេមកពិនិត្យទៅ។

**ស៖** តើលោកស្រីមានទឹកស្អាតសម្រាប់បរិភោគដែរឬទេ? ហើយទឹកនោះ ដែលគេយកមកឲ្យលោកស្រីហូបនោះ ទឹកនោះមកពីណាដែរ?

**ឆ៖** ទឹកហ្នឹង ទឹកគេដងនៅទឹកស្ទឹង តែគេដាំដែរ។

**ស៖** តើលោកស្រីធ្លាប់ហូបទឹកឆៅដែរឬទេ?

**ឆ៖** ចាស ដែរៗ ពេលអ្នកដាំ អត់ទាន់ទៅ ក៏ហូបទៅ ស្រេកខ្លាំង។

**ស៖** តើលោកស្រីមានដឹងដែរឬទេ ថានៅពេលដែលផឹកទឹកឆៅហ្នឹង លោកស្រីអាចធ្លាក់ខ្លួនឈឺអីចឹងខ្ញុំចង់សួរលោកស្រីថា ហេតុអីនៅពេលដែលដឹងថា ពេលហូបទឹកឆៅហ្នឹងអាចឈឺហើយ នៅតែ

ផឹកទឹកនៅហ្នឹងទៀត?

**ឆ៖** ដឹងដែរ តែបើយើងមិនហូប អត់មានអីហូប យើងទៅរកឯណា ចេះតែហូបទៅ។

**ស៖** បាទ ទាក់ទងទៅនឹងលំនៅ កន្លែងស្នាក់នៅ នៅក្នុងទំព័រទី៣ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី លោកស្រីបាននិយាយថា៖ “គេធ្វើរោងវែងៗ ដែលមានឈើតូចៗ ហើយនិងដាក់ក្រាលកន្ទេលពីលើ -- ស្លឹកឈើពីមើល ដែលមានកូនឈើវែងៗក្រាល។ ស្នាក់នៅរួម ហូបចុកជាសមូហភាព ប៉ុន្តែប្រុស ហើយនិងស្រីនៅកន្លែងផ្សេងៗពីគ្នា។” សូមបញ្ចប់ការដកស្រង់។ តើនៅពេលដែលលោកស្រីធ្វើការនៅការដ្ឋានហ្នឹង ការដ្ឋានទំនប់១មករា ហ្នឹងលោកស្រីសម្រាន្តគ្រប់គ្រាន់ទេ ស្រួលទេ ក្រោកឡើងទៅធ្វើការពេលព្រឹក ព្រលឹមឡើងនោះ?

**ឆ៖** ការរស់នៅ ដេកនៅកន្លែងហ្នឹង គេធ្វើរោងវែងឲ្យសម្រាក ប៉ុន្តែឈឺខ្នង ឈឺអី ពិបាកសង្កើចក៏ខាំ តែចេះតែទ្រាំ ហើយដែលធ្វើការអន់ពេក អត់ដឹងថាឈឺខ្លួន ហើយក៏សង្កើចខាំអី គឺថាភ្ញាក់ម្តង ក្រោកទៅហ្នុង ដឹងខ្លួន គឺគេហៅទៅទៀត។

[០៩:៥៧:៥៤]

**ស៖** មានមនុស្សជាច្រើននិយាយអំពីរុយ នៅពេលថ្ងៃ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា ពេលយប់ហ្នឹងតើមានមូសខាំលោកស្រីដែរឬទេ ឬក៏មានមុង មានអ្វីដើម្បីការពារកុំឲ្យមូសខាំលោកស្រីដែរឬទេ?

**ឆ៖** ចាស អត់មានមុងទេ ដេកហាលវាលតែម្តង មានតែកន្ទេលក្រាលទៅ ដណ្តប់ភួយទៅសម្រាកទៅ អត់មានមុង មានអីទេ។

**ស៖** ទាក់ទងសុខភាព ហើយនិងអនាម័យ លោកស្រីបាននិយាយនៅទំព័រទី៣ ជាភាសាបារាំង ហើយអង់គ្លេសទំព័រទី៤ ខ្មែរទំព័រទី -- អង់គ្លេសទី៣ ខ្មែរទំព័រទី៤ គេសួរលោកស្រីថា៖ “តើនៅទំនប់ហ្នឹង មានមនុស្សឈឺដែរ ឬទេ? លោកស្រីនិយាយថា គេមានអ្នកឈឺច្រើន ពីព្រោះធ្វើងារយ៉ាប់យឺនពេកហួសកម្លាំង បាក់កម្លាំង។ អ្នកទាំងអស់នោះមានជំងឺដូចជា ជំងឺគ្រុនក្តៅ ឬក៏ចុកពោះ។ នៅទីនោះមិនមានមន្ទីរពេទ្យទេ តែមានគ្រូពេទ្យដើរមើល និងមានថ្នាំពេទ្យ ថ្នាំអាចម៍ទន្សាយសម្រាប់អ្នកឈឺ ក្នុងករណីដែរឈឺធ្ងន់ គេបញ្ជូនមន្ទីរពេទ្យនៅឆ្ងាយពីការដ្ឋាន គេមិនទុកឲ្យស្លាប់នៅទីនោះទេ។” បាទ សូមបញ្ចប់ការដកស្រង់ចេញពីឯកសាររបស់លោកស្រី គឺឯកសារ D166/18។ បាទ លោកស្រីនិយាយថាមានមនុស្សជាច្រើនដែលធ្លាក់ខ្លួនឈឺ ដោយសារគេធ្វើការហួសកម្លាំង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា ហេតុអីបានអ្នកធ្វើការ ឬក៏លោកស្រីផ្ទាល់មិននិយាយប្រាប់មេរបស់លោកស្រីថា ហួសកម្លាំងធ្វើការមិនកើត

អស់កម្លាំងខ្លាំងពេក?

**ឆ៖** ចាស មិនប៊ាននិយាយប្រាប់ទេ។ ឈឺក៏ចេះតែទ្រាំទៅ ទាល់តែឈឺទៅមិនរួច បានប្រាប់គេ គេមកពិនិត្យដែរ។

**ស៖** បាទ យើងដឹងថាលោកស្រីមិនមែនជាពេទ្យ ឬក៏ ប៉ុន្តែ -- ឬក៏គិលានុបដ្ឋាយិការនោះទេ បើតាមលោកដឹង តើលោកស្រីដឹងថា តើជំងឺដែលញឹកញាប់ជាងគេ ដែលករណីច្រើនជាងគេ នៅការដ្ឋានហ្នឹង មានជំងឺអ្វីខ្លះ? លោកស្រីដឹងទេ?

**ឆ៖** មានជំងឺគ្រុនក្តៅ ឈឺពោះ ឈឺក្បាល ប៉ុណ្ណឹង។

[១០:០១:១៣]

**ស៖** តើកម្មករធ្លាប់សន្លប់នៅលើការដ្ឋានដែរឬទេ? ដោយសារតែគាត់អស់កម្លាំងពេក បាក់កម្លាំង មានមនុស្សសន្លប់ទេ?

**ឆ៖** ខាងក្រុមខ្ញុំមិនដែលមានទេ មានតែខ្យល់ចាប់។ ហេវហត់ពេកទៅខ្យល់ ហ្នឹងជួយកោស ជួយចាប់ទៅ ក៏បាត់ទៅ ក៏ធ្វើការទៀតទៅ។ តែឲ្យសន្លប់អត់ដែលឃើញទេ។ អត់មានទេ កន្លែងក្រុមខ្ញុំ។

**ស៖** លោកស្រីនិយាយថា គេមិនទុកឲ្យមនុស្សស្លាប់នៅទីនោះទេ ហើយគេយកអ្នកជំងឺធ្ងន់ហ្នឹងទៅមន្ទីរពេទ្យដែលនៅឆ្ងាយពីការដ្ឋាន។ តើអ្នកដែលគេដឹក -- តើអ្នកដែលគេយកទៅមន្ទីរពេទ្យឆ្ងាយហ្នឹងធ្លាប់មកវិញទេ? ឬក៏ទៅបាត់ខ្លួនរហូត?

**ឆ៖** អ្នកណាល្អមក៏ជាមកវិញទៅ។ បើអ្នកឈឺខ្លាំងក៏បាត់នៅទីនោះទៅ។

**ស៖** នៅក្នុងការបកប្រែជាភាសាបារាំងនៃសម្រង់ដែលខ្ញុំអានអម្បាញ់មិញនេះ គឺនិយាយអំពីពេទ្យដែលចុះទៅតាមការដ្ឋាន។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើពួកគេទាំងអស់នោះជាពេទ្យដែលបានទទួលការបណ្តុះបណ្តាលរយៈពេលវែងត្រឹមត្រូវតាមក្បួនច្បាប់វេជ្ជសាស្ត្រ ឬក៏គ្រាន់តែជាពេទ្យដែលទទួលការបណ្តុះបណ្តាលរយៈពេលខ្លី ហើយចុះទៅតាមការដ្ឋានមើលមនុស្សនោះ មើលព្យាបាលអ្នកជំងឺ?

**ឆ៖** ពេទ្យហ្នឹង គឺពេទ្យបណ្តុះបណ្តាលនៅពេលរយៈខ្លីទេ។ គេចាប់តាំងទៅក៏រៀនធ្វើទៅ។ អាជំងឺល្អមៗ ជំងឺខ្លាំងក៏មើលមិនជាដែរ។

**ស៖** ជាទូទៅ បួនប្រាំខែចុងក្រោយមក ក្រោយពីពេលបានធ្វើការនៅទីនោះហើយ តើលោកស្រីហើយនិងអ្នកសហការីរបស់លោកស្រីទាំងនុ៎ង មានសុខភាពល្អដដែលទេ ឬក៏កម្លាំងថមថយ ហើយស្គមជាដើម ធ្លាក់ខ្លួនស្គមជាដើមនោះ?

[១០:០៤:៣៥]

**ឆ៖** ខ្លះក៏មានកម្លាំងអន់ថយទៅ មានជំងឺទៅ។ ខ្លះក៏មិនអីទៅ តែនាងខ្ញុំមិនអីទេ។

**ស៖** អម្បាញ់មិញនេះ លោកស្រីបាននិយាយថា លោកស្រីរបួស ប៉ុន្តែទោះជាយ៉ាងណាក៏ត្រូវធ្វើការដែរ ក៏ត្រូវតែទៅធ្វើការដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា លោកស្រីរបួសអីដែរ?

**ឆ៖** របួសដូចជាមុតជើងមុតអី ដើរជំពប់នៅអ៊ីចឹង បែកជើងបែកដៃ ជំពប់ដុំថ្មីអ៊ីចឹង។

**ស៖** តើមានឈ្លប ឬអ្នកយាម ឬក៏យោធានៅការដ្ឋានទំនប់១មករាហ្នឹងដែរឬទេ ដែលពួកគេហ្នឹងមានបេសកកម្ម គឺឃ្លាំមើល ឬក៏យាមអ្នកធ្វើការនៅទីនោះ?

**ឆ៖** ចាស មានឈ្លប មានគេអ្នកយាម។ គេមើលអ្នកធ្វើការនៅទីនោះ។

**ស៖** លោកស្រីដឹងថាពួកគេមកពីណាដែរឬទេ មកពីឃុំ ពីស្រុកពីតំបន់ ឬក៏ពីភូមិភាគ?

**ឆ៖** មាននៅក្នុងឃុំហ្នឹងខ្លះ ហើយមកពីខាង ខ្ញុំមិនដឹងដែរ ដឹងតែត្រឹមភូមិឃុំ។ ច្រើនឈ្លបភូមិអីទៅយាម។

**ស៖** តើឈ្លបទាំងអស់ហ្នឹងមានអាវុធកាន់ដែរឬទេ?

**ឆ៖** ចាស មាន។

**ស៖** នៅពេលដែលលោកស្រីនិយាយថា ពួកគេយាមអ្នកធ្វើការ។ តើពួកគេធ្វើអីទៅឲ្យពិតប្រាកដ គេដើរល្បាត ឬក៏យ៉ាងម៉េច? តើតួនាទីពួកគេច្បាស់លាស់ហ្នឹងគឺធ្វើអ្វីដែរ?

**ឆ៖** ដើរល្បាត ដើរមើលអ៊ីចឹង ដើរល្បាតអ៊ីចឹង អត់មានធ្វើអីទេ ស្ពាយកាំភ្លើងទៅដើរមើលទៅទៅមកៗ។

**ស៖** តើក្នុងចំណោមមនុស្សដែលធ្វើការនៅការដ្ឋានហ្នឹង ប្រជាជនថ្មី ហើយនិងប្រជា -- ឬជនជាតិចាមហ្នឹងត្រូវបានគេឃ្លាំមើលខ្លាំងជាងគេ ឬក៏គេដាក់វិន័យហ្នឹងតឹងរ៉ឹងជាងគេ ឬក៏យ៉ាងណា?

**ឆ៖** ដាក់ដូចគ្នាៗនឹងប្រជាជនចាស់ក៏អ៊ីចឹង ប្រជាជនថ្មីក៏អ៊ីចឹងដែរ ដូចគ្នា។

[១០:០៨:៣៨]

**ស៖** នៅលើក -- នៅកន្លែងធ្វើការនោះ គេមានធ្លាប់និយាយប្រាប់លោកស្រី ពេលប្រជុំនោះ គេនិយាយអំពីខ្មាំងប្រឆាំងនឹងបដិវត្តន៍ហ្នឹង ហើយគេមាននិយាយប្រាប់លោកស្រីថាអ្នកណាជាខ្មាំងប្រឆាំងនឹងបដិវត្តន៍ដែរឬទេ?

**ឆ៖** ខ្ញុំអត់ឮនិយាយ ខ្ញុំអត់ចាំផង ភ្លេចហើយ។

**ស៖** តើអ្នកដែលប្រព្រឹត្តកំហុស ឬក៏ដែលរិះគន់ការងារសង់ទំនប់ហ្នឹង ឬក៏ដែលមិនព្រមធ្វើការងារហ្នឹង ត្រូវបានគេដាក់ទណ្ឌកម្មដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។ ខ្ញុំអត់ដែលដឹងទេ។

**ស៖** ព្រោះដោយសារតែនៅក្នុងកងរបស់លោកស្រីហ្នឹងមិនមានករណីហ្នឹងកើតឡើង ដែល -- ដោយហេតុអ៊ីចឹងហើយបានជាលោកស្រីមិនដឹង ឬក៏លោកស្រីនៅកងផ្សេងហ្នឹងមានករណីហ្នឹងដែរ?

**ឆ៖** នៅកងផ្សេងប្រហែលជាមាន ប៉ុន្តែខ្ញុំមិនដែលឮ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ នាពេលនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ អញ្ជើញចូលវិញ។

អញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរបន្ត!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រីសាក្សី ឥឡូវនេះ ខ្ញុំចង់និយាយអំពីវត្តបារាយណ៍ជាន់ដែក។ តើវត្តបារាយណ៍ជាន់ដែកនេះស្ថិតនៅក្នុងភូមិត្រស់ ឃុំប័ល្លង្កមែនទេ?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ចាស វត្តបារាយជាន់ដែកនៅក្នុងភូមិត្រស់ សង្កាត់បល្ល័ង្គ ស្រុកបារាយណ៍។

**ស៖** តើវត្តនេះ ជិតនឹងកន្លែងដែលលោកស្រីស្នាក់នៅដើម្បីធ្វើការនៅទំនប់ ១មករា មែនទេ?

**ឆ៖** ទំនប់មករា នៅឆ្ងាយពីវត្តនេះ ប្រហែលជា ១,៥គីឡូដី។

**សៈ** ខ្ញុំសូមអាននៅទំព័រ២ នៃកំណត់ហេតុ D166/18 គឺទំព័រ២ គ្រប់ភាសាទាំងអស់។ គេសួរលោកស្រីថា "លោកស្រីមានចាំថាមានការជម្លៀសដែរទេ? លោកស្រីបានឆ្លើយថា៖ ចំពោះខ្ញុំមិនមានការជម្លៀសទេ ប៉ុន្តែអ្នកផ្សេងមានការជម្លៀសពីកំពង់ចាម យកមកដាក់នៅវត្តបារាយណ៍ជាន់ដែក រួចសម្លាប់ចោលនៅទីនោះ។ ខ្ញុំមិនបានឃើញការសម្លាប់ទេ ព្រោះគេមិនឲ្យយើងចូលទៅ ប៉ុន្តែធុំក្លិនស្អុយចេញមកក្រៅ"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមព្យាយាមបំភ្លឺអំពីលោកស្រី ចំពោះខ្ញុំចម្លើយនេះដូចជាមិនច្បាស់ទេ។ លោកស្រីបាននិយាយថា អ្នកមកពីកំពង់ចាមហ្នឹងគេជម្លៀសទៅដាក់នៅវត្តបារាយណ៍ជាន់ដែក តើលោកស្រីចង់មានន័យថាម៉េច? គេបញ្ជូនទៅដាក់នៅវត្តហ្នឹងផ្ទាល់តែម្តង ឬក៏ដំបូងគេដាក់នៅវត្តនៅតាមភូមិ តាមឃុំ ឬក៏ដាក់នៅការដ្ឋាន ១មករាសិន ទើបបញ្ជូនទៅវត្តបារាយណ៍ជាន់ដែកនេះជាក្រោយ?

[១០:៣៣:៣៣]

**ឆៈ** គេជម្លៀសប្រជាជននេះ គេជម្លៀសមកពីខាងខេត្តកំពង់ចាម ហើយគេដឹកឡាន ខ្លះក៏ដឹករទេះគោយកមកចូលក្នុងវត្តហ្នឹង។ ក្នុងវត្តបារាយណ៍ជាន់ដែកហ្នឹង ឃើញតែគេចូលទៅ ពេលព្រលប់ៗអ៊ីចឹងមកហើយ ចូលហើយ។ ហើយចូលទៅដល់ស្ងាត់ហើយ ស្ងាត់ឈឹង។ អត់មានទុកនៅកន្លែងទំនប់អីណាទេ មកចូលនឹងវត្តហ្នឹងតែម្តង។

**សៈ** តើលោកស្រីអាចជម្រាបបានទេថា វត្តនេះគេប្រើជាមន្ទីរសន្តិសុខ ឬក៏យ៉ាងណា? ហើយវត្តនេះដំណើរការរយៈពេលប៉ុន្មានដែរ ក្នុងចន្លោះពីឆ្នាំ១៩៧៥ ទៅដល់ ៧៩?

**ឆៈ** សុំម្តងទៀត ខ្ញុំស្តាប់អត់ទាន់។

**សៈ** ខ្ញុំចង់ដឹងថា វត្តបារាយណ៍ជាន់ដែកនេះ ត្រូវបានគេប្រើជាមន្ទីរសន្តិសុខមែនទេ? គឺជាកន្លែង ដែលជាគេសម្លាប់មនុស្សមែនទេ? ហើយប្រសិនបើមែន ថាតើវត្តនេះដំណើរការជាមន្ទីរសន្តិសុខហ្នឹងអស់រយៈពេលប៉ុន្មានដែរចន្លោះពីឆ្នាំ៧៥ ដល់៧៩នោះ?

**ឆៈ** ចាស វត្តហ្នឹង គេធ្វើមន្ទីរសន្តិសុខ ហើយធ្វើជាសិប្បកម្មផងនៅក្នុងហ្នឹង ហើយអ្នកទោសអីចាប់យកទៅដាក់ក្នុងហ្នឹង ហើយខ្លះក៏គេសម្លាប់ទៅ ខ្លះក៏គេលែងទៅ។ តែប្រជាជនដែលគេបញ្ជូនមកគឺគេយកមកសម្លាប់តែម្តង។

[១០:៣៦:២៣]

**សៈ** បើសិនបើលោកស្រីមិនដឹងទេ លោកស្រីជម្រាបថាមិនដឹងទៅ។ ខ្ញុំចង់ដឹងថា តើអ្នកដែល

ធ្វើការនៅការដ្ឋានទំនប់១មករា មានត្រូវបានគេសម្លាប់នៅក្នុងមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែកហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ នៅក្នុងហ្នឹងខ្ញុំអត់ដឹងទេ អ្នកធ្វើទំនប់ហ្នឹងអត់ដឹង។ មិនដឹងគេសម្លាប់ឯណា។

**ស៖** តើលោកស្រីដឹងទេ ក្នុងចំណោមអ្នកដែលត្រូវគេសម្លាប់នៅវត្តបារាយណ៍ជាន់ដែកហ្នឹងមានជនជាតិចាម ដែលមកពីកំពង់ចាមទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ ដឹងតែគេដឹកមក ឃើញគ្រឹកៗហ្នឹង មិនដឹងថា ចាម ឬក៏ចិន ប៉ុនភាគច្រើន គឺដឹងថាប្រជាជនខ្មែរយើងសុទ្ធសាធ។

**ស៖** លោកស្រីបាននិយាយអំពីចំណុចមួយដែលខ្ញុំចង់បំភ្លឺ គឺនៅទំព័រ៣ ជាភាសាបារាំង, ២ ជាភាសាអង់គ្លេស និង ៣ ជាភាសាខ្មែរ។ លោកស្រីបាននិយាយថា៖ "អ្នកយាមស្ពាន ដូចជាចាមជាដើមហ្នឹងបានបាត់ខ្លួន ប៉ុន្តែខ្ញុំមិនដឹងមូលហេតុទេ"។ ខ្ញុំចង់ដឹងថាតើចាមហ្នឹងជា មានជាអ្នកយាមនៅការដ្ឋានហ្នឹងដែរ ឬក៏មានចាមហ្នឹងគ្រាន់តែជាអ្នកធ្វើការធម្មតាទេ មិនមែនជាអ្នកយាមទេ?

**ឆ៖** ចាម ហ្នឹងគឺកងចល័តនារីទេ នារីទេដែលបាត់ខ្លួនហ្នឹង នារីលីវ បាត់ខ្លួន។ គេហៅទៅ ក៏បាត់ឈឹង អត់ឃើញមកវិញ។

**ស៖** នារីហ្នឹងជាកម្មករ ឬក៏ជាអ្នកយាម ឬក៏ជាល្ពប?

**ឆ៖** នារីហ្នឹង វាគេដាក់ចូលក្នុងកងចល័ត។

[១០:៣៩:១៥]

**ស៖** លោកស្រីដឹងថា ហេតុអ្វីបានជាគាត់បាត់ខ្លួនទេ ហើយលោកស្រីអាចជម្រាបឈ្មោះបានទេ ប្រសិនបើលោកស្រីនៅចាំនោះ?

**ឆ៖** ខ្ញុំមិនដឹងមូលហេតុអីទេ តែស្រាប់តែគេហៅទៅ ក៏បាត់ទៅ។ នារីហ្នឹងឈ្មោះ មិត្តយ៉ាតជាជនជាតិចាម។

**ស៖** តើនៅការដ្ឋាននោះ ជនជាតិចាមមានសិទ្ធិប្រតិបត្តិសាសនាចាមទេ ហើយមានសិទ្ធិនិយាយភាសាចាមទេ?

**ឆ៖** ចាស អត់ទេ និយាយតែភាសាខ្មែរ។

**ស៖** តើចាមអាចស្លៀកពាក់ខោអាវប្រពៃណីរបស់ខ្លួនបានទេ ឧទាហរណ៍ដូចជាស្ត្រីអ៊ីចឹងអាច

នៅតែពាក់កន្សែងបានទេ?

**ផ៖** អត់ទេ គាត់ស្លៀកពាក់ខ្មែរ ដូចខ្មែរយើងអ៊ីចឹង។

**ស៖** ខ្ញុំនិយាយពីប្រធានបទផ្សេងនៅក្នុងភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ តើមានការផ្លាស់ប្តូរ ឬក៏មានការប្រែប្រួល នៅចន្លោះឆ្នាំ៧៧-៧៨នោះ គឺមានការផ្លាស់ប្តូរកម្មាភិបាលឬៗទេ? តើមានគេបោសម្អាតកម្មាភិបាលមួយចំនួន ហើយដាក់កម្មាភិបាលថ្មីមកជំនួសទេ?

**ផ៖** ចាស អត់មានទេ។

**ស៖** ខ្ញុំសូមអាននូវចម្លើយរបស់ កែ ពេជ្រវណ្ណៈ ដែលជាកូនរបស់ កែ ពក ជាប្រធានភូមិភាគ ដែលមាននិយាយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺ E3/35 ទំព័រ៦ ជាភាសាបារាំង, ៨ ជាភាសាអង់គ្លេស, ៧ ជាភាសាខ្មែរ។ សព្វថ្ងៃនេះ គាត់ស្លាប់ហើយ ក៏ប៉ុន្តែខ្ញុំសូមដកស្រង់ចម្លើយរបស់គាត់ “នៅពេលពួកនិរតីមកដល់ មានការបោសម្អាតនៅថ្នាក់ស្រុក រហូតទៅដល់ថ្នាក់ភូមិ។ ក្រោយពួកនិរតីមកដល់ តាប៉ូច គឺជាប្រធានស្រុកបារាយណ៍។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះ លោកស្រីប្រាកដទេថា លោកស្រីមិនបានឃើញពួកនិរតីមកចូលមកដល់ស្រុកបារាយណ៍ហ្នឹង ហើយមកកាន់មុខងារជាអ្នកធំនុ៎ង?

**ផ៖** ចាស ខ្ញុំអត់ដឹងទេ អត់ស្គាល់។

[១០:៤២:៣៨]

**ស៖** ចុះលោកស្រីធ្លាប់ឮគេនិយាយអំពី តាប៉ូច ទេ? គាត់ជាប្រធានស្រុកបារាយណ៍ហ្នឹង?

**ផ៖** ចាស ឮតែឈ្មោះ ប៉ុន្តែខ្ញុំមិនដែលស្គាល់ផង មិនស្គាល់។

**ស៖** តើលោកស្រីអាចជម្រាបបានទេ ថានៅការដ្ឋានហ្នឹង លោកស្រីអាចប្រតិបត្តិសាសនាបានទេ?

**ផ៖** ចាស អត់ទេ អត់ដែលប្រតិបត្តិអីទេ មានបានធ្វើអីទេ។

**ស៖** គេហាមមិនឲ្យគោរពសាសនា ឬក៏យ៉ាងម៉េច?

**ផ៖** គេៗហាមមិនឲ្យគោរពសាសនាទេ។ ធ្វើបុណ្យ ក៏គេមិនឲ្យធ្វើដែរ។

**ស៖** ក្នុងពេលប្រជុំ តើគេមានប្រាប់ទេថា ប្រសិនបើអ្នកណាម្នាក់ប៉ានគោរពសាសនានុ៎ង នឹងមានហេតុការណ៍អ្វីកើតឡើងចំពោះអ្នកនោះ ហើយនិងអាចមានគ្រោះថ្នាក់ចំពោះអ្នកដែលប៉ានគោរពសាសនា។ គេមានបាននិយាយអ៊ីចឹងទេ?

**ឆ៖** គេៗមិនដែលប្រាប់ទេ តែគេមិនឲ្យធ្វើ គេមិនឲ្យយើងធ្វើតាមហ្នុង បើសាសនាព្រះពុទ្ធសាសនា។

**ស៖** ក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅការដ្ឋានសាងសង់ទំនប់១មករា តើលោកស្រីត្រូវតែគោរពដាច់ខាត ចំពោះបញ្ជានិងសេចក្ដីណែនាំរបស់មេរបស់លោកស្រី មែនទេ?

**ឆ៖** ចាស ខ្ញុំត្រូវតែគោរព។ ខ្ញុំ -- បើមិនធ្វើតាមគេ គេកសាងយើង។ គេស្ដីឲ្យទៅ។ ចេះតែខំប្រឹងធ្វើតាម ធ្វើទៅ។

**ស៖** លោកនិយាយអំពីការកសាង ឬក៏ការដាក់វិន័យ។ អ៊ីចឹងខ្ញុំចឹងដឹងថា តើមានវិធានការវិន័យអ្វីខ្លះ ប្រសិនបើលោកស្រីមិនគោរពតាមបញ្ជារបស់មេលោកស្រីនោះ? គេធ្វើយ៉ាងម៉េចខ្លះចំពោះលោកស្រី?

**ឆ៖** គេស្ដីឲ្យអីទៅ។ គេឲ្យប្ដេជ្ញាចិត្ត ថ្ងៃក្រោយឲ្យឈប់ធ្វើអ៊ីចឹង ទៅណាឲ្យឆាប់មកទៅ ទាន់ពេលម៉ោង ពេលវេលាគេធ្វើការ។

[១០:៤៦:២៦]

**ស៖** ខ្ញុំដឹងថាលោកស្រីមិននៅយូរទេ គឺត្រឹមតែបួនប្រាំខែប៉ុណ្ណឹងនៅការដ្ឋាននោះ។ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា លោកស្រីមានស្គាល់ឈ្មោះ ទ្រី ទេ? គាត់ក៏មកពីភូមិត្រស់ ដែរ? ហើយគាត់ហ្នឹងប្រហែលជាត្រូវបានគេដាក់ទណ្ឌកម្ម។

**ឆ៖** ចាស ស្គាល់ឈ្មោះ ទ្រី ហ្នឹង។ តែកាលណោះ ទ្រី ហ្នឹងនៅក្មេងៗ ប្រហែលជាអាយុជាង ១០ឆ្នាំ, ១៤-១៥ អីទៅហ្នឹង។ ក្មេងហ្នឹងឈ្មោះ ទ្រី។ ចាស ខ្ញុំស្គាល់។

**ស៖** ខ្ញុំមិនដឹងថាយើងនិយាយអំពី ទ្រី តែមួយ ឬក៏យ៉ាងម៉េច? តើ ទ្រី ហ្នឹងគាត់ធ្វើការនៅការដ្ឋានទំនប់ ១មករា ហ្នឹងទេ? ហើយលោកស្រីដឹងថា មានហេតុការណ៍អ្វីកើតឡើងចំពោះឈ្មោះ ទ្រី ហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំមិនសូវដឹងដែរឈ្មោះ ទ្រី ហ្នឹង គ្រាន់តែថាស្គាល់ឈ្មោះ ទ្រី មែន។ តែខ្ញុំសូវដឹងទេពីហេតុការណ៍នោះ។

**ស៖** តើ ទ្រី ហ្នឹងគាត់ធ្វើការនៅការដ្ឋានសាងសង់ទំនប់ ១មករា ហ្នឹងទេ?

**ឆ៖** ចាស ធ្វើ។ ធ្វើរែកដី រែកអ៊ីចឹង។

[១០:៤៧:០៥]

**ស៖** អម្បាញ់មិញនេះ លោកស្រីថា ជាមធ្យមគឺអ្នកធ្វើការហ្នឹងមានអាយុ២០ឆ្នាំ។ ក៏ប៉ុន្តែនៅទីនេះយើងនិយាយអំពី ទ្រី គឺគាត់អាយុ ១៤-១៥ឆ្នាំទេ។ តើអ៊ីចឹងមានអ្នកណាផ្សេងទៀតដែលមានអាយុប្រហែលជា ១៤-១៥ឆ្នាំ ដូច ទ្រី ហ្នឹងទេ?

**ឆ៖** ចាស ដូចជាគ្មាន។ តាមឃើញដូចជាគ្មានទេ។ ទ្រី ហ្នឹងនៅក្នុងភូមិត្រស់ដែរ។ មានតែមួយហ្នឹង។

**ស៖** ក្រោយឆ្នាំ១៩៧៩ មកហ្នឹង លោកស្រីធ្លាប់ឃើញឈ្មោះ ទ្រី ហ្នឹងទៀតទេ? គាត់នៅរស់រាន់មានជីវិតទេ ក្រោយរបបខ្មែរក្រហមមក?

**ឆ៖** ចាស មិនមានទេ។ អត់ឃើញ អត់រហូត។

**ស៖** តើលោកស្រីមានធ្លាប់ឮគេនិយាយអ្វីពាក់ព័ន្ធទៅនឹងមូលហេតុអ្វីដែល ទ្រី បាត់ខ្លួនទេ? ហើយធ្លាប់ឮគេនិយាយថា តើ ទ្រី ហ្នឹងគេនាំទៅណា? ឬក៏បាត់ខ្លួននៅកន្លែងណាអីទេ?

**ឆ៖** ចាស ខ្ញុំឮ ធ្លាប់ឮដែលថា ទ្រី ហ្នឹងគេយកទៅសម្លាប់ហើយ។ គេដាក់ឲ្យយាមស្ពាន។

**ស៖** នៅពេលដែលអ្នកធ្វើការត្រូវទៅបត់ដៃបត់ជើងហ្នឹង គឺត្រូវចេញពីការដ្ឋាន ហើយទៅចូលទៅបត់ដៃបត់ជើងនៅក្នុងព្រៃដែលនៅក្បែរនោះៗ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន ឈប់ធ្វើការចូលក្នុងព្រៃបត់ដៃបត់ជើង ព្រោះវាអត់មានបង្គន់អនាម័យអីទេ។

[១០:៥០:៤៧]

**ស៖** តើនៅពេលដែលទៅបត់ដៃបត់ជើងនៅក្នុងព្រៃហ្នឹង មានអ្នកយាមគេទៅតាម គេប្រាប់ថាបត់ដៃបត់ជើងឲ្យលឿន ប្រញាប់ទៅធ្វើការវិញអ៊ីចឹងទេ?

**ឆ៖** ចាស អត់ទេ អត់មានទេ គេនៅតែកន្លែងគេ។

**ស៖** នៅក្នុងព្រៃជិតៗនោះ តើលោកស្រីធ្លាប់ឃើញមានមនុស្សត្រូវគេយកទៅដាក់ឃុំក្នុងទ្រុងដែលគេធ្វើពីកូនឈើទេ?

**ឆ៖** ចាស ខ្ញុំមិនដែលឃើញទេ។ មិនដែលបានចូលព្រៃជ្រៅទេ ខ្ញុំខ្លាចណាស់ អត់ហ៊ានចូល។

**ស៖** នៅក្នុងកងរបស់អ្នកស្រី តើមានអ្នកណាធ្លាប់និយាយថា គាត់ធ្លាប់បានឃើញមានទ្រុងដើម្បីគេយកដាក់មនុស្សដែលធ្វើខុស ដើម្បីឲ្យកសាងខ្លួនអ៊ីចឹង។ មានអ្នកណានៅក្នុងកងលោកស្រីធ្លាប់ប្រាប់លោកស្រីថាអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអត់ដែលដឹងទេ គ្មានអ្នកណាដែលប្រាប់ខ្ញុំទេ អត់ដឹង។

**ស៖** ខ្ញុំចូលទៅប្រធានបទចុងក្រោយ។ អម្បាញ់មិញនេះ លោកស្រីនិយាយថា នៅពេលដែលថ្នាក់លើមកត្រួតពិនិត្យការដ្ឋាន គេប្រាប់ឲ្យលោកស្រីធ្វើការឲ្យបានខ្លាំងជាងមុន ហើយឲ្យរែកដីរត់។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកស្រីធ្លាប់ឃើញមានជនបរទេសណាមួយចុះមកមើលការដ្ឋានសាងសង់ហ្នឹងទេ? ឧទាហរណ៍ដូចជាជនជាតិចិន ឬក៏មានប្រតិភូស្ត្រីវៀតណាម ឡាវអី ធ្លាប់ឃើញពួកគាត់មកទស្សនកិច្ចនៅទីនុំងទេ?

**ឆ៖** ចាស ខ្ញុំមិនដែលឃើញទេ ព្រោះកន្លែងខ្ញុំរែកដីនោះវាឆ្ងាយពីកន្លែងគេ កន្លែងអ្នកធំគេមកពិនិត្យមកអី ខ្ញុំឆ្ងាយពីគេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ។ ខ្ញុំអត់សំណួរហើយ ខ្ញុំសូមប្រគល់វេទិកានេះជូនដើមបណ្តឹងរដ្ឋប្បវេណីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:៥៤:០២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រធាន។ ជម្រាបសួរភាគីទាំងអស់គ្នា អស់លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ជាមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកស្រី។ លោកស្រីបាននិយាយបន្តិចបន្តួចកាលពីព្រឹកមិញថាលោកស្រីបានរៀបការនៅពេលណាមួយនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ តើនៅឆ្នាំណាដែរ ហើយបើអាចចាំបាននោះ ខែណាដែរ ដែលលោកស្រីបានរៀបការនោះ?

**លោកស្រី កង អ៊ុត៖**

**ឆ៖** នាងខ្ញុំបានរៀបការនៅឆ្នាំ១៩៦៧ ថ្ងៃ -- ខ្ញុំភ្លេចហើយថ្ងៃ មិនដឹងថ្ងៃណាទេ ចាំតែ១៩៦៧ --៧៧។

[១០:៥៥:១៩]

**ស៖** សូមអរគុណ។ តើអ្នកណាជាអ្នករៀបចំពិធីការលោកស្រីហ្នឹង?

**ឆ៖** គេហៅថា អង្គការៗ គេរៀបឲ្យ។ គ្នាច្រើន រៀបចំនួន២៥គូ តែមិនមែនរៀននៅនឹងភូមិទេ តែរៀបឯឆ្ងាយ នៅគេហៅភូមិដូង។ អង្គាល់នោះ គេហៅឈ្មោះ ប្រធានទុំងគេហៅឈ្មោះប្រធាន ប៊ិន គេរៀបឲ្យ។

**ស៖** សូមអរគុណ។ ឪពុកម្ដាយលោកស្រីនោះ តើពួកគាត់ទាំងអស់គ្នាហ្នឹងគេមានសួរយោបល់ពួកគាត់ទាំងអស់គ្នាទេទាក់ទងនឹងការរៀបការរបស់លោកស្រីនេះជាមួយនឹងមេកងលោកស្រីនេះ គេមានពិគ្រោះយោបល់គាត់ទេ?

**ឆ៖** ចំពោះប្រធានគេអត់មានទៅពិគ្រោះទេ តែម៉ែៗសងខាងគាត់បាននិយាយគ្នារួចអស់ហើយ គាត់ដឹងដែរ។

**ស៖** មុននឹងពេលលោកស្រីរៀបការជាមួយប្ដីលោកស្រីហ្នឹង តើលោកស្រីស្គាល់គាត់ពីមុនមកទេ?

**ឆ៖** ចាស ខ្ញុំស្គាល់ ព្រោះនៅភូមិជាមួយគ្នា ភូមិត្រស់ជាមួយគ្នា។

[១០:៥៧:៤៨]

**ស៖** តើលោកស្រីដឹងថាលោកស្រីត្រូវរៀបការហ្នឹងតាមរបៀបណាដែរ? តើលោកស្រីដឹងថាលោកស្រីត្រូវរៀបការជាមួយនឹងប្ដីលោកស្រីហ្នឹងដោយប្រធានភូមិ ឬក៏មេកងហ្នឹងប្រាប់លោកស្រីនៅពេលណា? គេប្រាប់លោកស្រីនៅពេលណាថា ដល់ពេលនេះត្រូវតែរៀបការនោះ?

**ឆ៖** គេប្រាប់ថា ដូចត្រូវដល់ថ្ងៃស្អែកអ៊ីចឹង គេប្រាប់ពីថ្ងៃហ្នឹងទៅ ត្រូវតែរៀបការ។

**ស៖** បើខ្ញុំមិនច្រឡំទេ លោកស្រីនិយាយថា គេប្រាប់លោកស្រីមុននឹងថា មួយថ្ងៃមុនថ្ងៃរៀបការទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ប៉ុន្តែម្ដាយឪពុកគាត់ដឹងតាំងពីថ្ងៃមុនហើយ។

**ស៖** តើគេមានពន្យល់ប្រាប់លោកស្រីដែរឬទេថា ហេតុអីក៏អង្គការជាអ្នករៀបការលោកស្រីទៅវិញ?

**ឆ៖** គេមិន -- ដូចជាមិនដឹងពន្យល់អីទេ ប៉ុន្តែគេធ្វើមីទ្ទិងដែរ ខ្ញុំភ្លេចអស់ហើយ។

[១០:៥៩:៥៦]

**ស៖** នៅពេលដែលគេប្រាប់លោកតែមួយថ្ងៃមុននេះ ដែលថាស្អែកឡើងហ្នឹងត្រូវតែរៀបការ។ ពេលហ្នឹង តើលោកស្រីទទួលអារម្មណ៍យ៉ាងណាដែរនៅពេលនោះ?

**ឆ៖** ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនទៅ មិនចង់ទៅ តែគេមកតាមពីរបីជើង ក៏ទៅៗ។

**ស៖** តើនៅពេលនេះលោកស្រីមានអារម្មណ៍ថា លោកស្រីមានសិទ្ធិសេរីភាពក្នុងការជំទាស់មិនរៀបការដែរឬទេ?

**ឆ៖** ចាស ខ្ញុំមិនហ៊ានជំទាស់ទេ។ បើយើងជំទាស់ គេថាយើងប្រឆាំង។ ប្រឆាំងនឹងអង្គការម៉្លោះហើយខ្ញុំមិនជំទាស់ទេ ក៏តាមគេទៅ។

**ស៖** នៅសម័យនោះ តើលោកស្រីមានស្គាល់បុរសហ្នឹងនារីដែលគេឲ្យរៀបការ ហើយពួកគាត់នោះបានជំទាស់មិនព្រមរៀបការដែរឬទេ?

**ឆ៖** ចាស មិនមានទេ។ នៅភូមិខ្ញុំគ្មានទេ។ មិនជំទាស់ទេ ព្រោះមិនហ៊ានជំទាស់ផង។ គេឲ្យរៀបក៏រៀបតែម្តង។

[១១:០១:៥២]

**ស៖** អម្បាញ់មិញហ្នឹង លោកស្រីដូចជានិយាយថា មាន២៥គូ។ អ៊ីចឹងខ្ញុំចង់ចោទសំណួរទាក់ទងនឹងពិធីការនេះ។ តើលោកស្រីនៅចាំទេ ថាអ្នកណាជាអ្នកដឹកនាំរៀបចំពិធីការនេះ?

**ឆ៖** ចាស ខ្ញុំភ្លេចអស់ហើយ មិនដឹងជាអ្នកណាទេ ដឹកនាំ ភ្លេចហើយ យូរហើយ។ ហើយរៀបការនេះ គឺរៀបឆ្ងាយពីផ្ទះ មិននៅក្នុងភូមិត្រស់ទេ គឺនៅខាងភូមិដូង។

**ស៖** តើលោកស្រីចាំដែរឬទេថា កាលដែលគេរៀបចំពិធីការនេះ រៀបចំពិធីការនៅម៉ោងប៉ុន្មានដែរ?

**ឆ៖** គេចាប់ផ្តើមហៅទៅតាំងៗពីម៉ោងពីរ គេឲ្យទៅអង្គុយតម្រៀបគ្នាទៅ រហូតដល់ម៉ោងបួនម៉ោងប្រាំ គេធ្វើមីទ្ទិង ហើយគេឲ្យ គេកាប់គោឲ្យហូបបាយនៅហ្នឹង អ្នកដែលរៀបការហ្នឹង។

**ស៖** ពេលដែលលោកស្រីនិយាយថា “ពួកគេ” មកយកយើងនុ៎ង លោកស្រីចង់សំដៅទៅលើអ្នកណាពួកគេនុ៎ង?

**ឆ៖** ខ្ញុំភ្លេចឈ្មោះហើយ។ ភ្លេចឈ្មោះគេៗអ្នកមកតាមហើយ ពួកនៅគេហៅ “សង្កាត់” អង្កាល់នុ៎ង។ ពួកសង្កាត់ គេមកតាម។

[១១:០៤:២៩]

**ស៖** ពេលរៀបការនោះ លោកស្រីមានថ្លែងសេចក្ដីប៉ងប្រាថ្នាអ្វីទេ ឬក៏អ្នករៀបចំពិធីការហ្នឹង គេប្រាប់ឲ្យលោកស្រីប្ដេជ្ញាអីដែរឬទេ?

**ឆ៖** គេឲ្យប្ដេជ្ញាតែម្ដងទេ ម្នាក់ទៅលើប្ដេជ្ញាទៅរួចទៅ ទាំងអស់គ្នាទៅ។ តែខ្ញុំៗ អត់មានឡើងទេ។

**ស៖** ហេតុអ្វីបានជាលោកស្រីមិនបានធ្វើ?

**ឆ៖** ចាស គេមិនហៅខ្ញុំផង គេហៅតែម្នាក់ឡើងតំណាងទៅ គេនិយាយទៅ ហើយក៏រួចទៅ ហើយម្ចាស់ -- ប្រធានគេឡើងធ្វើមីទ្ទិងទៅ ក៏ចប់ទៅ ហូបបាយទៅ ក៏ចប់ទៅ។

**ស៖** ហើយអ្នកដែលតំណាងឲ្យអ្នករៀបការគ្នាដែរហ្នឹង គេតំណាងឲ្យគូផ្សេងទៀតទាំងអស់ហ្នឹងឬក៏យ៉ាងម៉េច អ្នកដែលឡើងប្ដេជ្ញាជំនួសគេហ្នឹង គឺតំណាងឲ្យអ្នកទាំងប៉ុន្មានគូដែលនៅសេសសល់ទាំងប៉ុន្មានហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** ចាស គេឡើងឲ្យតំណាងឲ្យអ្នកទាំងអស់ហ្នឹង អ្នកទាំង២៥ហ្នឹង។

[១១:០៦:២៩]

**ស៖** តើលោកស្រីនៅចាំដែរឬទេ ថាតើអ្នកតំណាងហ្នឹងគាត់បាននិយាយអំពីអ្វីខ្លះ គាត់ឡើងប្រកាស ឬក៏ឡើងប្ដេជ្ញាហ្នឹង ពេលគាត់ឡើងប្ដេជ្ញា គាត់និយាយអីខ្លះ?

**ឆ៖** ចាស ខ្ញុំភ្លេចអស់ហើយ ខ្ញុំអត់ចាំទេ។

**ស៖** តើឪពុកម្ដាយរបស់លោកស្រីមានបានចូលរួមក្នុងពិធីបុណ្យរៀបការលោកស្រីនេះដែរឬទេ?

**ឆ៖** ចាស អត់ទេ គាត់អត់ទៅ។ គេអត់ហៅទៅ ហៅទៅតែសាមីខ្លួន។

**ស៖** តើលោកស្រីអាចពន្យល់ជូនតុលាការបានដែរឬទេ ថាពិធីការនុ៎ងខុសពីពិធីការដែលគេធ្វើនៅមុនរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងយ៉ាងម៉េចដែរ? ចង់និយាយថា ពីមុនមកពេលគេរៀបអាពាហ៍ពិពាហ៍ គេធ្វើយ៉ាងដូចម្ដេច ហើយខុសគ្នាពីការរៀបអាពាហ៍ពិពាហ៍នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងយ៉ាងម៉េចដែរ ឬក៏ដូចនោះ ដូចត្រង់ចំណុចណាដែរ?

[១១:០៨:០៦]

**ឆ៖** ចាស គ្មានដូចពិធីការពេលនៅសព្វថ្ងៃនេះទេ។ គ្មានដូច គឺខុសទាំងអស់។

**ស៖** លោកស្រីអាចនិយាយឲ្យបានលម្អិតបានដែរឬទេ ដែលលោកស្រីនិយាយថា មិនដូចទាល់

តែសោះនោះ តើមិនដូចត្រង់ចំណុចណាខ្លះ? ឧទាហរណ៍ថា តើមានព្រះសង្ឃដែរឬទេ? មានការប្រគេនចង្ហាន់អីដែរឬទេ? មានភ្លេងដែរឬទេ? ហើយអ៊ីចឹងអាចជម្រាបជូនតុលាការបានដែរឬទេ ថាមុនរបបខ្មែរក្រហមនោះពិធីរៀបការគេធ្វើយ៉ាងដូចម្ដេចខ្លះ? ហើយក្រោយរបបខ្មែរក្រហមគេធ្វើយ៉ាងដូចម្ដេចខ្លះ? ហើយក្នុងរបបខ្មែរក្រហមហ្នឹង ពេលរៀបការគេធ្វើយ៉ាងដូចម្ដេចខ្លះ? ចូលរៀបរាប់ឲ្យបានលម្អិតពីភាពដូចគ្នា និងខុសគ្នា។

**ធ៖** ខុសគ្នា។ ពេលរៀបការគេមានហែកំណត់ គេកាត់សក់ គេកាត់អី មានភ្លេង មានស្អីៗទៀត សូត្រមន្តស្អី មានច្រើនណាស់ តែប៉ុល ពត គ្មានស្អីទេ មានតែអង្គុយហើយ ធ្វើមីទ្និងបន្តិចបន្តួចក៏ចប់ទៅហើយ។ អត់មានដូចគេទេ ខ្ញុំមិនសូវចេះនិយាយទេ តែប៉ុណ្ណឹង។

**ស៖** លោកស្រីសាក្សី ខ្ញុំសូមអរគុណហើយដែលបានផ្ដល់ព័ត៌មានលម្អិតនេះ ខ្ញុំគិតថាជាការលំបាកណាស់ដែលនិយាយអំពីអតីតកាលដែលកន្លងមកជាយូរមកហើយមកនេះ។ តើពេលដែលពិធីហ្នឹងធ្វើចប់ហើយ លោកស្រីនិយាយអម្បាញ់មិញហ្នឹង គឺថាមានឲ្យស្រស់ស្រូបអាហារ ហើយខ្ញុំសួរថាតើក្រោយពីស្រស់ស្រូបអាហារហើយហ្នឹង តើគូរៀបការទាំងប៉ុន្មានហ្នឹង ត្រូវធ្វើអ្វី មានកាតព្វកិច្ចអ្វីដែលត្រូវតែធ្វើដែរឬទេ?

**ធ៖** ការធ្វើតែមីទ្និងរួច ហូបបាយរួចហើយអ៊ីចឹង ក៏ចប់ទៅ គេឲ្យមកផ្ទះរៀងៗខ្លួនមក។

[១១:១១:០៥]

**ស៖** បើខ្ញុំមិនច្រឡំទេ គឺថាលោកស្រីមិនបាននៅជាមួយប្ដីលោកស្រី នៅរាត្រីទីមួយទេ។ អ៊ីចឹងមែនទេ?

**ធ៖** ចាស អត់ទេ មកផ្ទះ។

**ស៖** តើក្រោយពីរាត្រីដំបូងនេះហើយហ្នឹង មានពេលណាមួយហ្នឹង លោកស្រីបានជួបជុំជាមួយប្ដីលោកស្រីវិញដែរឬទេ?

**ធ៖** ចាស គេឲ្យនៅជាមួយ៣ថ្ងៃ រួចពីហ្នឹង គេបំបែកធ្វើការរៀងខ្លួន។ ប្ដីទៅធ្វើមុខព្រួញផ្សេងទៅ ប្រពន្ធទៅផ្សេងទៅ តែ១០ថ្ងៃ គេឲ្យមកជួបគ្នាម្ដង។

**ស៖** ខ្ញុំសូមអរគុណ។ តើមានឈ្លបមកលបស្ដាប់លោកស្រីដែរឬទេ នៅពេលដែលលោកស្រីនៅជាមួយប្ដីលោកស្រីនៅយប់ដំបូងនោះ មានឈ្លបមកលួចស្ដាប់ដែរឬទេ?

**ធ៖** ចាស អត់ទេ អត់មានអ្នកណាមកទេ។

**ស៖** ខ្ញុំសូមអានសក្ខីកម្មមួយដែលឆ្លើយមកទីនេះ នៅថ្ងៃទី២៦ ឧសភា គាត់និយាយថា គាត់មកពីភូមិរបស់លោកស្រីដែរ ហើយគាត់ការនៅឆ្នាំ១៩៧៧ដូចលោកស្រីដែរ នៅថ្ងៃទី២៦ ខែឧសភា។ នៅទីនេះ គាត់ឆ្លើយថា គឺឯកសារ E1/350 ម៉ោងប្រាំបួន -- 305 ម៉ោង០៩:៤៥នាទី គាត់និយាយថា មានឈ្លបគេមកលបមើល ចង់ដឹងថាតើយើងចុះសម្រុងនឹងគ្នាឬអត់ តើៗយើងអុជធូប ឬសែនព្រេនអីឬក៏អត់។ បើសិនគេឃើញដូច្នោះ គេនឹងសម្លាប់យើង។ នៅៗម៉ោង០៩:៤៧នាទី គាត់និយាយថា គេមិនតាមដានតែខ្ញុំទេ ឈ្លបនោះ គេៗតាមដានមើលគ្រប់អ្នករៀបការថ្មីថ្មោងទាំងអស់។ តើលោកស្រីមានដឹងហេតុការណ៍នេះទេថា ឈ្លបហ្នឹងគេ តែងតែទៅឃ្លាំមើលលបស្តាប់អ្នកដែលទើបនឹងរៀបការថ្មីថ្មោងហ្នឹងទាំងអស់?

**ផ៖** ចាស ខ្ញុំអត់ដឹងទេ អត់ៗមាន ខ្ញុំអត់មានទេ។

[១១:១៤:២៤]

**ស៖** អម្បាញ់មិញលោកស្រីបាននិយាយថា លោកស្រីបានរៀបការជាមួយគាត់ហើយ មានកូនពីរ។ អ៊ីចឹងខ្ញុំសួរថា កូនពីរនាក់ហ្នឹង គឺជាកូនដែលលោកស្រីបានជាមួយនឹងបុរសដែលលោកស្រីរៀបការនៅក្នុងឆ្នាំ១៩៧៧ ឬក៏យ៉ាងណា?

**ផ៖** ចាស មានកូនជាមួយហ្នឹង ជាមួយគាត់ដែលរៀបការហ្នឹងនៅឆ្នាំ១៩៧៧ ខ្ញុំមានកូនពីរនាក់ហ្នឹង។

**ស៖** តើកូនរបស់លោកស្រីកើតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងណា? ចង់និយាយថា គាត់កើតមុនឆ្នាំ១៩៧៩ ឬក៏ក្រោយឆ្នាំ១៩៧៩?

**ផ៖** ចាស កូនខ្ញុំកើតនៅឆ្នាំ១៩៨១ ហើយ។

**ស៖** ខ្ញុំដូចជាយល់មិនច្បាស់ទេ។ លោកស្រីសព្វថ្ងៃនេះ នៅជាមួយប្តីលោកស្រីដដែល ឬក៏យ៉ាងណា?

**ផ៖** ចាស ខ្ញុំនៅជាមួយប្តីដដែល។ ប្តីមានតែមួយហ្នឹង។

[១១:១៦:៤៩]

**ស៖** លោកស្រីសាក្សី ខ្ញុំមិន យល់មិនច្បាស់ ដោយសារអម្បាញ់មិញ ខ្ញុំមិនដឹងថាលោកស្រីនៅជាមួយគាត់ដដែល។ នៅពេលដែលរៀបការ លោកស្រីនិយាយថាមាន២៥គូ។ តើលោកស្រីមានឱកាសអាចជួបគូផ្សេងៗទៀតដែលរៀបការជាមួយលោកស្រីនៅថ្ងៃនោះដែរឬទេ ក្រោយមក?

**ផ៖** ចាស ខ្ញុំមិនដែលជួបទេនៅភូមិឆ្ងាយពីគ្នា។ គេទៅខាងភូមិគេទៅ ខ្ញុំមកខាងភូមិខ្ញុំ។ មិននៅក្នុងភូមិតែមួយឯណា។

**ស៖** លោកស្រីជាអ្នករៀបការតែមួយគូគត់អង្គាល់នោះនោះ គឺមកពីភូមិត្រស់ អ៊ីចឹងមែនទេ? ឬក៏មានគូផ្សេងទៀតដែលមកពីភូមិត្រស់ដែរ?

**ផ៖** ចាស ភូមិត្រស់ហ្នឹងមានពីរគូទាំងខ្ញុំ។ មានតែពីរគូទេដែលទៅរៀបនៅភូមិដូងហ្នឹង។

**ស៖** បាទ ខ្ញុំយល់ហើយ។ ខ្ញុំមានសំណួរចុងក្រោយមួយ។ តើលោកស្រីដឹងថា កាលសម័យនោះ ថាតើគេអាចរៀបការ ប្រជាជនថ្មីនិងប្រជាជនចាស់ហ្នឹង អាចរៀបការជាមួយគ្នាបានដែរឬទេ? ឬក៏ប្រជាជនចាស់ អាចរៀបការបានតែប្រជាជនចាស់? ប្រជាជនថ្មីអាចរៀបការបានតែជាមួយប្រជាជនថ្មីទេ? តើលោកស្រីដឹងថា កាលនោះគេមានច្បាប់ទម្លាប់អីកំណត់ឲ្យ ហៅថាបើប្រជាជនចាស់ត្រូវតែរៀបការជាមួយប្រជាជនចាស់ បើប្រជាជនថ្មីត្រូវតែរៀបការជាមួយប្រជាជនថ្មីដែរទេ?

[១១:១៩:០៣]

**ផ៖** ចាស កាលនោះ គេរៀបបានតែប្រជាជនចាស់ទេ។ ប្រជាជនថ្មីគេ -- បើសិនរៀបៗ ជាមួយប្រជាជនថ្មី តែមិនទាន់មានរៀបទេកាលឆ្នាំ៧៧ មិនទាន់រៀបទេប្រជាជនថ្មី រៀបតែប្រជាជនចាស់។

**ស៖** បើតាមការយល់ដឹងរបស់លោកស្រី តើវិធានការ ឬក៏ច្បាប់ដែលគេកំណត់នោះចូលជាធរមាននៅពេលណាដែរ?

**ផ៖** ចាស ខ្ញុំអត់ដឹងទេ។

**ស៖** លោកស្រីបាននិយាយថា លោកស្រីបានរៀបការនោះ គឺថាមាន២៥គូ។ តើលោកស្រីមានដឹងថា មានវិធីរៀបការផ្សេងទៀតទេ ដែលត្រូវបានគេរៀបចំឡើងក្រោយពេលដែលលោកស្រីបានការនោះ? ហើយដែលពេលរៀបការក្រោយៗហ្នឹងគឺអាចមានមនុស្សដែលមកពីភូមិត្រស់ហ្នឹងក៏រៀបការដែរតើមានទេ លោកស្រីមានដឹងថាគេរៀបចំពិធីការក្រោយៗទៀតមកទេ ក្រោយឆ្នាំ៧៧ហ្នឹង?

**ផ៖** ចាស អត់មានទេ។

[១១:២០:៥៥]

**ស៖** អ៊ីចឹងបើតាមលោកស្រីដឹងថា ការរៀបការ២៥គូ នេះគឺជាពិធីរៀបការតែមួយគត់ទេដែលត្រូវបានគេប្រារព្ធឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឃុំរបស់លោកស្រី? តើលោកស្រីចង់និយាយថាអ៊ីចឹង ឬក៏យ៉ាងម៉េច មានការរៀបការតែម្តងហ្នឹងទេ?

**ឆ៖** ចាស មានការរៀបការតែម្ដងហ្នឹង ដូចគ្មានឃើញរៀបទៀត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

លោកស្រីសាក្សី ខ្ញុំសូមអរគុណដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ ខ្ញុំចប់ត្រឹមប៉ុណ្ណេះ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរតែពីរទេ តូចៗទេសួរទៅសាក្សីនេះសូមការបំភ្លឺមួយចំនួន។ ប្រហែលជាខ្ញុំស្ដាប់មិនច្បាស់ក៏មិនដឹង តើពេលលោកស្រីធ្វើការនៅទំនប់១មករានេះ លោកស្រីមានឃើញគេចាប់មនុស្សដែរឬទេ? តើមានការបាត់ខ្លួនមនុស្សដែរឬទេនៅទំនប់១មករានេះ?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ចាស ខ្ញុំមិនដែលឃើញគេចាប់ទេ តែមានមនុស្សបាត់ខ្លួន គឺជនជាតិចាមនារីដែលចល័តហ្នឹង តែម្នាក់ហ្នឹង។ ស្រាប់តែបាត់ទៅ តែឲ្យឃើញគេចាប់ពពាក់ពពួន គឺខ្ញុំមិនដែលឃើញទេ។

[១១:២៣:១៥]

**ស៖** កាលពីព្រឹកមិញលោកស្រីបាននិយាយអំពីវត្តបារាយណជាន់ដែក។ លោកស្រីបាននិយាយថា លោកស្រីបានឃើញថាមានគេនាំមនុស្សទៅទីនោះជាច្រើន គេយកទៅដាក់នៅទីនោះ។ តើលោកស្រីដឹងថា មនុស្សដែលលោកស្រីឃើញគេនាំយកទៅវត្តបារាយណ៍ជាន់ដែកនេះ មានចំនួនប៉ុន្មានដែរ លោកស្រីអាចឲ្យចំនួនប្រហាក់ប្រហែលបានទេ?

**ឆ៖** ទេ ខ្ញុំមិនដឹងថាប៉ុន្មានទេ មិនអាចសន្និដ្ឋានទេ តែដឹកឡានក៏មាន ដឹករទេះគោក៏មាន មិនដឹងជាប៉ុន្មាន ព្រោះអីខ្ញុំមិនប៊ានចេញទៅមើលទេ វាយប់ ព្រលប់ៗហើយ។

**ស៖** ការនាំមនុស្សទៅដាក់វត្តបារាយណ៍ជាន់ដែកហ្នឹង គឺកើតឡើងជាទៀងទាត់ ចង់និយាយថារាល់ថ្ងៃ ឬក៏យូរៗម្ដង លោកស្រីអាចជម្រាបជូនតុលាការបានទេ?

**ឆ៖** ចាស យូរៗម្ដងទេ យូរៗមកម្ដងអ៊ីចឹងទៅ មិនមករាល់ថ្ងៃទេ។

**ស៖** ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីបានត្រឡប់ទៅវត្តបារាយណ៍ជាន់ដែកដែរឬទេ?

**ឆ៖** ចាស ត្រឡប់មកនៅផ្ទះវិញ នៅក្បែរនុំងដែរ។ នៅជិតរបងវត្តដែរផ្ទះហ្នឹង។

**ស៖** តើលោកស្រីមានដឹងដែរឬទេថាតើគេមានបានឃើញសាកសពដែលកប់នៅម្តុំវត្តបារាយណ៍ជាន់ដែកហ្នឹងដែរឬទេ ហើយបើសិនជាមានមែន បើលោកស្រីដឹងនោះ ថាតើសាកសពនុំងមានចំនួនប៉ុន្មានដែរ?

**ឆ៖** យូរ ដាច់ទៅឃើញរណ្តៅបួនប្រាំដែរ តែមិនដឹងជាសាកសពប៉ុន្មានទេ ឃើញតែរណ្តៅធំៗដែរ ហើយគេគាស់កកាយ ហើយនៅសល់តែក្បាល រួចគេរើសទុកធ្វើជាខក្រិដ្ឋកម្មទុកនៅសព្វថ្ងៃនេះនៅវត្តបារាយណ៍ជាន់ដែកហ្នឹង។

[១១:២៦:៥២]

**ស៖** ហើយឆ្អឹងលលាដ៍ក្បាល ហើយនិងឆ្អឹងទាំងអស់ហ្នឹង ទៅដាក់ចូលក្នុងចេតិយណាមួយទុកកន្លែងណាមួយ ឬក៏គេយកឆ្អឹង ហើយនិងលលាដ៍ក្បាលទាំងអស់ហ្នឹងទៅណាអស់ហើយ?

**ឆ៖** ចាស គេអត់យកទៅណាទេ គេទុកនៅ តាំងនៅហ្នឹង ដល់គេធ្វើជាចេតិយនៅទុកនៅក្នុងវត្តហ្នឹងហើយគេទុក គេបង្សុកូលអីឲ្យរាល់ឆ្នាំ។

**ស៖** តើនៅក្នុងគ្រួសាររបស់លោកស្រីមានអ្នកណាបាត់ខ្លួន ឬក៏ត្រូវបានគេសម្លាប់ដែរឬទេ នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** នៅក្នុងនោះ គ្មានទេ គ្រួសារខ្ញុំ គឺអត់មាន។

**ស៖** តើនៅក្នុងភូមិនុំង ក្នុងចំណោមប្រជាជនមូលដ្ឋាននោះ តើមានអ្នកណាបាត់ខ្លួននៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងដែរឬទេ?

**ឆ៖** ចាស មានខ្លះដែរ។ តែភាគច្រើន ច្រើនតែអ្នកមកពីចម្ងាយ។

**ស៖** អ៊ីចឹង គឺអ្នកបាត់ខ្លួនភាគច្រើននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យដែលនៅក្នុងភូមិរបស់លោកស្រីនោះ គឺសុទ្ធតែជាអ្នកមកពីកន្លែងផ្សេង ហើយសុទ្ធតែជាប្រជាជនថ្មី។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។ ច្រើន ភាគច្រើនប្រជាជនថ្មី។

[១១:២៨:៤៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកស្រីសាក្សី ខ្ញុំអស់សំណួរហើយ។

លោកប្រធានអរគុណ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកចៅក្រម។

ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះឈប់នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងអញ្ជើញរូបគាត់ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ វេលាម៉ោងមួយកន្លះរសៀលនេះ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលមានពេលវេលាមួយរសៀលនេះ ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

ជាដំបូងអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។

សូមអញ្ជើញ លោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំមាននូវសំណួរតិចតួចទេ នៅថ្ងៃរសៀលនេះ។ បាទខ្ញុំសូម

ចាប់ផ្តើមសួរលោកស្រីសំណួរមួយចំនួនតូច ពាក់ព័ន្ធទៅនឹងការរៀបការរបស់លោកស្រី។ លោកស្រីបានឆ្លើយនៅមុនពេលឈប់សម្រាកពិសាបាយថ្ងៃត្រង់ថា មកដល់ -- សព្វថ្ងៃនេះ លោកស្រីនៅតែរស់នៅជាមួយប្តីលោកស្រីដែលការតាំងពីឆ្នាំ៧៧។ ហើយខ្ញុំស្តាប់ឮថា គាត់ក៏មកពីភូមិជាមួយគ្នានឹងភូមិរបស់លោកស្រីដែរ។ តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះថា ហេតុអ្វីបានជាបុរសម្នាក់នេះ ត្រូវបានគេរើស ឱ្យៗរៀបផ្សំផ្គុំឱ្យជាប្តីរបស់លោកស្រី? ម៉េចក៏មិនរើសបុរសផ្សេងមកពីភូមិផ្សេងអ៊ីចឹង?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ចំពោះរឿងនេះខ្ញុំមិនដឹងដែរ។ ប្រធានភូមិគេផ្គុងផ្តើមជាគូទៅ ក៏គេប្រាប់ម្តាយ ប្រាប់ឪពុកទាំងសងខាងទៅ ក៏គាត់បានត្រូវរ៉ូវគ្នាទៅ ក៏គាត់ព្រមស្រុះស្រួលឱ្យរៀបទៅ ឱ្យរៀបការទៅ។ តែប៉ុណ្ណឹង។

**ស៖** តើលោកស្រីចាំទេថា ពេលនុ៎ងឪពុកម្តាយរបស់លោកស្រីហ្នឹង មានប្រតិកម្មយ៉ាងម៉េចដែរនៅពេលដែលគេជ្រើសរើសបុរសរូបនេះឱ្យធ្វើជាប្តីលោកស្រី?

**ឆ៖** គាត់អត់មានជំទាស់អីទេ ព្រោះអីប្តីខ្ញុំនេះជាសាច់ញាតិនឹងគាត់ទាំងសងខាង។

[១៣:៣២:៤២]

**ស៖** ចុះលោកស្រីផ្ទាល់ លោកស្រីមានប្រតិកម្មអីដែរ ឬក៏លោកស្រីយល់ស្រប យល់ព្រមជាមួយនឹងការជ្រើសរើសនេះដែរ?

**ឆ៖** ចាស ខ្ញុំយល់ស្របដែរទៅតាមម្តាយឪពុក។

**ស៖** ឥឡូវ និយាយអំពីយប់ទី១ក្រោយពីលោកស្រីរៀបការជាមួយប្តីលោកស្រីហើយ តើលោកស្រី ហើយនិងប្តីលោកស្រីនេះ មានមុងៗដេកទេ នៅយប់ទី១ពេលការហើយហ្នឹង?

**ឆ៖** ចាស អត់មានទេ គ្មានៗមុងទេ។ សម្រាកនៅក្នុងបន្ទប់ មានតែកន្ទេល ភួយ ខ្នើយតែប៉ុណ្ណោះ។

**ស៖** ហើយលោកស្រីដឹងទេ ហេតុអីបានជាមិនមានមុង?

**ឆ៖** វាព្រោះកាលនោះ គ្មានទេមុង។ សម្រាកតែហាលវាលអ៊ីចឹង។

**ស៖** ដូច្នេះ អ៊ីចឹងនៅទំនប់១មករាហ្នឹង លោកស្រីអត់មានមុងដេកហ្នឹង គឺដោយសារតែគេមិនមានមុងតែម្តង។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស គ្មានមុងតែម្តង គ្មានមុងរហូត។ ពេលធ្វើការនុ៎ងក៏គ្មានមុងដែរ ដេកហាលវាលដែរ។

[១៣:៣៥:០០]

**ស៖** សំណួរខ្ញុំបន្ទាប់ គឺសួរអំពីអំឡុងពេលដែលលោកស្រីធ្វើការនៅឯការដ្ឋានទំនប់ ១មករា។ ព្រឹកមិញនេះ លោកស្រីថាលោកស្រីបានធ្វើការនៅទំនប់ប្រហែលជាបួនប្រាំខែ។ តើអាច លោកស្រីថាអាចជាធ្វើការបានតែ៣ខែ ឬក៏យ៉ាងណា? មិនមែនបួន មិនមែនប្រាំ គឺប្រហែលជាអាចត្រឹម៣ខែ។ បើខ្ញុំគិតអ៊ីចឹងយ៉ាងម៉េចដែរ?

**ឆ៖** ចាស ប្រហែលជាត្រឹមប៉ុណ្ណឹងមែនក៏មិនដឹង តែខ្ញុំភ្លេចដែរ យូរហើយ។

**ស៖** ខ្ញុំយល់ហើយលោកស្រីសាក្សី។ តើនៅពេលនោះ ហេតុអ្វីបានជាលោកស្រីត្រូវទៅធ្វើការនៅ -- គេចាត់តាំងឲ្យលោកស្រីទៅធ្វើការនៅទីនោះតែ៣ខែ?

**ឆ៖** កាលនោះ ក៏ខ្ញុំរៀបគ្រួសារទៅ គេដកពីកងចល័តឲ្យ គេដាក់ទៅវ៉ៃយកណ្ដាល។ គេឲ្យដើរធ្វើតាមមុខព្រួញឆ្ងាយៗ។

**ស៖** ប្រហែលជាខ្ញុំរៀបចំសំណួរមិនបានល្អ។ អ្វីដែលខ្ញុំចង់សួរលោកស្រីនោះថា តើលោកស្រីត្រូវបានគេប្រាប់ថាលោកស្រីនិងអ្នកដទៃទៀត ហេតុអ្វីបានជាលោកស្រី និងអ្នកដទៃទៀតត្រូវបានចាត់តាំងឲ្យទៅធ្វើការតែរយៈពេល៣ខែអ៊ីចឹង? ម៉េចក៏មិនធ្វើ២ខែ ឬក៏៤ខែវិញទៅ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៣:៣៧:០៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំដូចជាពិបាកសំណួរនេះ ព្រោះថាសាក្សីហ្នឹងគាត់និយាយថាពី៤ទៅ៥ខែ។ ឥឡូវលោកមេធាវីគាត់និយាយថាប្រហែលជា៣ខែទៅវិញ គាត់ថាមិនចាំជាពេលវេលាណា។ អ៊ីចឹង មើលទៅមេធាវីនិយាយមកធ្វើដូចជា ហាក់ដូចជាគាត់នៅទីនោះត្រឹមតែ៣ខែដូចគាត់ហ្នឹងច្បាស់ណាស់អ៊ីចឹង មើលទៅវាខុសពីអ្វីដែលយើងបានឮចេញពីពាក្យសម្ដីរបស់លោកស្រីសាក្សីដែលនិយាយកាលពីព្រឹកមិញលោកប្រធាន។ អ៊ីចឹង ខ្ញុំសុំបដិសេធ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងរៀបសំណួរខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** លោកស្រី តើនៅពេលនុ៎ងមានគេប្រាប់ថាហេតុអ្វីជាលោកស្រីត្រូវគេឲ្យទៅធ្វើការនៅក្នុងពេលមួយមានកម្រិតបែបនេះ? ម៉េចមិនធ្វើយូរជាងនេះឬក៏យ៉ាងណាទៅ? តើគេមានប្រាប់ថាម៉េចៗដែរ ឬក៏លោកស្រីមិនចាំទេ?

**លោកស្រី កង អ៊ុតៈ**

**ឆៈ** ចាស ខ្ញុំមិនចាំទេ។

**សៈ** តើលោកស្រីដឹងថា គេមានការផ្លាស់ប្តូរវេនគ្នាទេ ទៅធ្វើការនៅកន្លែងនុ៎ង?

**ឆៈ** ចាស គ្មានផ្លាស់ទេ។ អ្នកនៅធ្វើនៅហ្នឹង នៅតែធ្វើ ទាល់តែរួច។

**សៈ** តើមានការផ្លាស់ប្តូរវេនទាំងក្រុម ទាំងកងតែម្តងទេ? លោកស្រីថាក្រោយពេលលោកស្រីធ្វើការនៅទំនប់ ១មករា លោកស្រីត្រូវបានគេចាត់តាំងឲ្យទៅៗធ្វើស្រែ។ តើការផ្លាស់ប្តូរវេនទៅធ្វើបែបហ្នឹង គេប្តូរវេនដល់ក្រុមដទៃទៀតដែរទេ? មានន័យថាប្តូរវេនទាំងក្រុមតែម្តង?

**ឆៈ** ចាស់អត់ទេ នៅក្នុងក្រុមគេនៅតែធ្វើ តែចំពោះអ្នកមានគ្រួសារគេដកដាក់ទៅវ៉ៃយកណ្តាលឲ្យទៅធ្វើស្រែ។

**សៈ** សូមអរគុណលោកស្រីសាក្សី។ នៅពេលលោកស្រីធ្វើការនៅការដ្ឋានទំនប់១មករា តើលោកស្រីមានពេលឈប់សម្រាករៀងរាល់ ១០ថ្ងៃម្តងទេ?

**ឆៈ** ចាស មាន ១០ថ្ងៃគេ ចូនខ្ញុំសម្រាកមួយថ្ងៃ។

[១៣:៤០:២៥]

**សៈ** តើថ្ងៃឈប់សម្រាកហ្នឹង គឺជាថ្ងៃដែលលោកស្រីទទួលបាននូវបង្អែមអីចឹង ជួនកាលថ្ងៃឈប់សម្រាកហ្នឹងជាថ្ងៃដែលទទួលបានបង្អែមផងដែរឬ?

**ឆៈ** ចាស ១០ថ្ងៃហ្នឹងគេសម្រាក គេធ្វើបង្អែមម្តងឲ្យហូប។

**សៈ** ហើយតើថ្ងៃហ្នឹងគឺជាថ្ងៃដែលលោកស្រីមានសិទ្ធិសេរីភាពហើយគេអនុញ្ញាតឲ្យលោកស្រីធ្វើអ្វីៗតាមតែចិត្តចង់បានដែរឬទេ?

**ឆៈ** ចាស បាន។

**សៈ** ឥឡូវនិយាយពីការដ្ឋានការងារនេះផ្ទាល់តែម្តង។ តើត្រឹមត្រូវទេម៉ោងការងារ គឺមានពេលប្រកាសឲ្យឈប់សម្រាក គេប្រើជួងសម្រាប់វាយឲ្យអ្នកធ្វើការទាំងអស់ឮនៅទំនប់១មករា។ អីចឹងឬក៏អត់ទេ?

**ឆ៖** ចាស មាន ដល់ម៉ោងគេវាយជួងហើយ ដល់ឈប់សម្រាកគេវាយជួងឲ្យឈប់ ពេលចេញពីធ្វើការគឺគេវាយជួងទៀត។

**ស៖** តើជួងដែលគេវាយនោះ តើគេវាយជួងហ្នឹងសម្រាប់អ្នកធ្វើការទាំងអស់ សម្រាប់អ្នកភូមិទាំងអស់ សម្រាប់កងទាំងអស់ ឬក៏ជួងនេះគឺថាវាយសម្រាប់តែកងរបស់លោកស្រីទេ?

**ឆ៖** ចាស គេវាយសម្រាប់អ្នកទាំងអស់គ្នា។ ដល់ម៉ោងធ្វើទាំងអស់គ្នា។

**ស៖** តើលោកស្រីដឹងថា មេភូមិមកពីឃុំរបស់លោកស្រីនោះ មេភូមិឈ្មោះ ឱ ហូ លោកស្រីស្គាល់ទេ?

**ឆ៖** ឈ្មោះ ហូ ស្គាល់ចាស។

**ស៖** តើគាត់ពិតជាមេភូមិរបស់លោកស្រីមែនទេ?

**ឆ៖** គាត់ជាមេនៅក្តាប់ក្តោបនឹងកន្លែងការដ្ឋានហ្នឹង។

[១៣:៤៣:៣៤]

**ស៖** មេភូមិរូបនេះក៏បានមកផ្តល់សក្ខីកម្មអំពីពេលម៉ោងការងារ បានជម្រាបជូនតុលាការអំពីម៉ោងការងារ។ ឥឡូវ ខ្ញុំសូមអានចម្លើយរបស់គាត់ឲ្យលោកស្រីស្តាប់ ហើយសួរលោកស្រីទៅតាមចំណុចនីមួយៗ។ លោកប្រធានគឺឯកសារ E3/5255, ERN ជាភាសាអង់គ្លេស 00250046, បារាំង 00277227, ខ្មែរ 00239909។ “សំណួរ៖ តើគេចាប់ផ្តើមធ្វើការនៅម៉ោងប៉ុន្មាន និងចប់នៅម៉ោងប៉ុន្មាន? ចម្លើយ៖ គេចាប់ផ្តើមធ្វើការនៅម៉ោង៦ព្រឹក បន្តរហូតទៅដល់ម៉ោង១២ ហើយបានចាប់ផ្តើមពីម៉ោង២ ដល់ម៉ោង៥ និងចាប់ផ្តើមធ្វើការបន្តទៀតពីម៉ោង៧ ដល់ម៉ោង១០យប់”។

នៅពេលព្រឹក ម៉ោងការងារសម្រាប់ពេលព្រឹក គាត់និយាយថា ប្រជាជននៅភូមិរបស់គាត់នោះមិនមែនផ្តើមធ្វើការនៅម៉ោងបួនទេ ប៉ុន្តែចាប់ផ្តើមធ្វើការនៅម៉ោងប្រាំមួយកន្លះទៅវិញទេ។ សាក្សីដទៃខ្លះទៀតថា ចាប់ផ្តើមធ្វើការនៅម៉ោងប្រាំពីរ។ ហើយលោកស្រីឆ្លើយពីខាងមុននេះថាចាប់ផ្តើមធ្វើការនៅម៉ោងបួន។ តើលោកស្រីយល់ថាម៉េចដែរចំពោះចម្លើយរបស់សាក្សីទាំងនេះដែលនិយាយអំពីម៉ោងការងារនេះ ខុសគ្នាបែបនេះ?

**ឆ៖** នៅម៉ោងប្រាំពីរព្រឹកគឺគ្មានទេ ម៉ោងប្រាំពីរព្រឹកមានតែការសម្រាក១៥នាទី ដែលកាលពេលខ្ញុំធ្វើ។ តែបើខ្ញុំឈប់ទៅខ្ញុំមិនដឹងដែរ។

[១៣:៤៥:៥៤]

**ស៖** ចុះពេលសម្រាកបាយថ្ងៃត្រង់ គឺចន្លោះពីម៉ោងដប់មួយ ទៅម៉ោងមួយ ឬៗក៏ពីម៉ោងដប់មួយ ឈប់សម្រាកបាយថ្ងៃត្រង់រហូតដល់ម៉ោងពីរ?

**ឆ៖** សម្រាកថ្ងៃត្រង់នៅម៉ោងដប់មួយ ពេលធ្វើការនៅម៉ោងមួយ។

**ស៖** ខ្ញុំក៏បានសួរសំណួរដូច្នេះនេះដែរ ទៅ សួរទៅសាក្សីម្នាក់ឈ្មោះ មាស ឡៃហួរ មកពីកងរបស់លោកស្រីដែរ។ នៅថ្ងៃទី២៦ ខែឧសភា ២០១៥ នៅប្រហែលជាម៉ោង ១០:៤៨ គាត់បានបញ្ជាក់ថា "ឈប់សម្រាកបាយថ្ងៃត្រង់ហ្នឹង គឺពីម៉ោងដប់មួយរហូតដល់ពីរ"។ តើពេលឈប់សម្រាកបាយថ្ងៃត្រង់ហ្នឹង គឺពីម៉ោងដប់មួយដល់ម៉ោងពីរ ឬក៏ពីម៉ោងដប់មួយទៅដល់ម៉ោងមួយ?

**ឆ៖** ចាស ចំពោះខ្ញុំពីម៉ោងដប់មួយ រហូតថាម៉ោងមួយចេញធ្វើការហើយ។

**ស៖** នៅពេលនោះ លោកស្រីមាននាឡិកាប្រើប្រាស់ទេ?

**ឆ៖** ចាស ខ្ញុំគ្មាននាឡិកាប្រើទេ ប៉ុន្តែគេកំណត់តែម៉ោងមួយ សួរគេម៉ោងមួយ គេវាយជួងទៅចេញទៅ។

**ស៖** ប៉ុន្តែ តើលោកស្រីធ្វើម៉េចបានដឹងថាវាម៉ោងមួយ?

[១៣:៤៨:០៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវីកូប៉េ ខ្ញុំដូចមានអារម្មណ៍ថាលោកអាន ដោយផ្អែកនៃចម្លើយរបស់លោក ឱ អ៊ួ គឺឯកសារ E3/5255 មែនទេ? បាទ ឱ ហួ បាទ សុំទោស។ បាទ គឺឯកសារ E3/5255 ហ្នឹងមែនទេ?

**លោក វិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយគឺឯកសារ E3/5255។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ អ៊ីចឹងខ្ញុំសូមអាន៖ "ការងារចាប់ផ្តើមម៉ោងប្រាំមួយកន្លះ រហូតដល់ម៉ោងដប់មួយ ហើយចាប់ផ្តើមម្តងទៀតពីម៉ោងពីរទៅដល់ម៉ោងប្រាំល្ងាច។ ហើយពីល្ងាចពីម៉ោងប្រាំពីរដល់ម៉ោងដប់យប់។" ហើយខ្ញុំសូមអានផ្អែកបន្តទៀត "ដើម្បីឲ្យចប់ផែនការនោះ អ្នកធ្វើការត្រូវធ្វើការតាំងពីម៉ោងបួនព្រឹករហូតទៅដល់ម៉ោងដប់មួយ ហើយពីម៉ោងពីរ ទៅដល់ម៉ោងប្រាំរសៀល ហើយពេលយប់ហ្នឹងពីម៉ោងប្រាំពីរដល់ម៉ោងដប់"។ តើលោកមានអត្ថបទដូចគ្នានឹងខ្ញុំដែរឬទេ ឬក៏យ៉ាងណា?

[១៣:៤៩:២៥]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំអានវាចេញពីប្រតិចារឹកលោកចៅក្រម នៅឃ្លាទី២នេះ "គឺ ដើម្បីបញ្ចប់ទំនប់ហ្នឹងគឺចាប់ផ្តើមពីម៉ោងបួនរហូតដល់ម៉ោងដប់មួយ ចាប់ផ្តើមពីម៉ោងពីរទៅដល់ម៉ោងប្រាំ ហើយក៏ចាប់ផ្តើមពីម៉ោងប្រាំពីរទៅដល់ម៉ោងដប់យប់"។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

មើលទៅប្រហែលជាលោកហ្នឹងប្រាកដជាអានធ្វើជាភ្លេចតែម្តង។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំសូមសួរលោកស្រី អំពីលោកស្រីឈប់សម្រាក គឺពេលល្ងាចឈប់សម្រាកនៅម៉ោងប្រាំមែនទេ?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ចាស នៅពេលម៉ោងប្រាំ។

**ស៖** ចុះការងារនៅពេលយប់ តើគេធ្វើជារៀងរាល់យប់ ឬក៏គេធ្វើក្នុងពេលពិសេសណាមួយទេ?

**ឆ៖** ចាស គេធ្វើរាល់យប់។

**ស៖** ខ្ញុំក៏បានសួរសំណួរដដែលទៅដល់អ្នកធ្វើការនៅកងជាមួយលោកស្រី គឺ មាស ឡៃហួរ គាត់បានឆ្លើយថា គាត់បានឆ្លើយជម្រាបជូនអង្គជំនុំជម្រះនៅថ្ងៃទី២៦ ឧសភា ឆ្នាំ២០១៥ នៅម៉ោង ១០:៤៥ គាត់បានឆ្លើយថា គាត់យល់ស្របថា ការងារនៅពេលយប់ហ្នឹង គេធ្វើតែនៅពេលពិសេសៗណាមួយទេ។ តើចម្លើយរបស់គាត់នេះ ត្រឹមត្រូវដែរឬទេ? ចម្លើយមួយណាត្រឹមត្រូវ? ចម្លើយរបស់គាត់ត្រឹមត្រូវ ឬក៏ចម្លើយរបស់លោកស្រីត្រឹមត្រូវ ដែលគាត់ឆ្លើយថាគេធ្វើតែនៅពេលពិសេសណានោះ?

[១៣:៥១:១៧]

**ឆ៖** មិនមានពេលពិសេសទេ ចំពោះខ្ញុំធ្វើយប់រាល់តែថ្ងៃ ធ្វើថ្ងៃណាក៏ធ្វើយប់ដែរ។

**ស៖** ខ្ញុំសូមសួរលោកស្រីនៅសំណួរចុងក្រោយ។ លោកស្រីចាំទេថា ដើម្បីកុំឲ្យមានរុយ គឺថានៅពេលនោះ គេមានបាញ់ថ្នាំសម្លាប់សត្វល្អិត មានគេបាញ់ថ្នាំសម្លាប់សត្វល្អិតទេ?

**ឆ៖** ចាស ខ្ញុំមិនដែលឃើញទេ។ ខ្ញុំទៅធ្វើការបាត់ទៅ ដឹងគេបាញ់មែនដឹង អីមិនដឹង មិនដែលឃើញផង។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងឈ្លបដែលលោកស្រីឆ្លើយថាលោកស្រីបានឃើញ។ លោកស្រីអាចជម្រាបជូនតុលាការបានទេ តើកន្លែងដែលលោកស្រីបានឃើញហ្នឹងនៅចម្ងាយប៉ុន្មានពីកន្លែងការដ្ឋានការងារ? តើឈ្លបហ្នឹងគេឈរនៅចន្លោះអ្នកធ្វើការ ឬគេឈរឆ្ងាយចម្ងាយប៉ុន្មានពីអ្នកធ្វើការ?

**ឆ៖** ឈ្លបហ្នឹង គេនៅឆ្ងាយ គេដើរមើលតែខាងក្រៅៗ។ គេដើរយាម។

**ស៖** តើលោកស្រីដឹងថា ឈ្លបហ្នឹងគេឈរបែរមើលទៅព្រៃទៅអ៊ីចឹងដើម្បីធានាសន្តិសុខ ដើម្បីកុំឱ្យវាមានការចូលមកឆ្លងឆ្លើយ ឬមានការគំរាមកំហែងណាមួយពីអ្នកខាងក្រៅ ឬក៏អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** ចាខ្ញុំមិនបានពិនិត្យដែររឿងឈ្លប អាល័យតែខំប្រឹងធ្វើការខ្លាចគេកសាង មានបានជាពិនិត្យឈ្លបទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយសហការីមេធាវីជាតិនៅមានសំណួរផងដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។

[១៣:៥៤:១៧]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីនៅក្នុងក្រុមការពារក្តីលោក នួន ជា។ ខ្ញុំបាទមានសំណួរបន្តិចបន្តួចសាកសួរបន្ថែមចំពោះលោកស្រី។ អំមិញលោកស្រីបានឆ្លើយតាមសំណួររបស់សហភាតាខ្ញុំថា ប្រធានភូមិបានផ្គូផ្គងលោកស្រីជាមួយនឹងប្តីលោកស្រីហើយបានយកមកពិគ្រោះយោបល់ជាមួយនឹងឪពុកម្តាយទាំងសងខាង ហើយលោកស្រីបានឆ្លើយថែមទៀតថា លោកស្រីបានរៀបការទៅតាមការរៀបចំរបស់ឪពុកម្តាយ។ អ៊ីចឹងបើសិនជាខ្ញុំសង្ខេបថា ការរៀបការរវាងលោកស្រី ហើយនិងប្តីលោកស្រីជាការសម្រេចចិត្តរបស់ឪពុកម្តាយទាំងសងខាង មិនមែនជា

ការសម្រេចចិត្តរបស់ប្រធានភូមិទេ តើលោកស្រីយល់ស្របដែរឬទេ?

**លោកស្រី កង អ៊ិត៖**

**ឆ៖** ចាស ខ្ញុំសម្រេចតាមឪពុកម្ដាយ ខ្ញុំយល់ស្រប។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

លោកប្រធាន វាហួសពេលបាត់ទៅហើយ ពីព្រោះកាលមុនហ្នឹង គាត់និយាយថា គឺជាមេគាត់ជាអ្នកជ្រើសរើស ហើយបន្ទាប់មកគេប្រាប់ដំណឹងហ្នឹងទៅឪពុកម្ដាយរបស់គាត់ ហើយក្រោយមកហ្នឹងគាត់ផ្ទាល់ គាត់យល់ព្រម ពីព្រោះថាឪពុកម្ដាយគាត់ហ្នឹងមិនដឹងថាគាត់បានយល់ស្របតាមការជ្រើសរើសតាមមេប្រធានគាត់ ឬក៏យ៉ាងណា ឬក៏គាត់មិនព្រម ឬក៏ព្រមនោះទេ ក៏ប៉ុន្តែដោយសារតែមេរើសហើយគាត់ព្រមទៅ។ ហើយសំណួរអម្បាញ់មិញនេះ ខ្ញុំយល់ឃើញថាជាការនាំមុខ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១៣:៥៦:៣៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំគិតថា យើងអាចបន្តទៅមុខទៀតបានលោកប្រធាន ព្រោះថាការជំទាស់អម្បាញ់មិញនេះដូចគ្មានឃើញមូលដ្ឋានអីទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តសំណួរ!

**សួរដោយលោក លីវ សុវណ្ណា៖**

បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបន្តសំណួរខ្ញុំ។

**ស៖** លោកស្រី មានសាក្សីមួយចំនួនបានមកផ្ដល់សក្ខីកម្មនៅទីនេះថា ពេលដែលធ្វើការពេលយប់គឺធ្វើការនៅពេលដែលខែភ្លឺ ហើយលោកស្រីបានមានប្រសាសន៍ថា ធ្វើការរៀងរាល់យប់។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំសូមសួរថា តើធ្វើការពេលយប់នេះបានពន្លឺអ្វីដើម្បីមើល ដើម្បីធ្វើការបាន?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណ។ ខ្ញុំមិនចង់កាត់ផ្តាច់រាល់ដងនោះទេ ប៉ុន្តែបើសិនជាមេធាវីការពារក្តី គាត់យោងទៅលើសក្ខីកម្មណាមួយដែលទាក់ទង ដែលបានលើកឡើងអំពីការធ្វើការនៅក្រោមពន្លឺព្រះចន្ទនោះ គួរតែលើកឡើង ដូចថាគាត់និយាយនៅពេលណា នៅកន្លែងណាឲ្យច្បាស់លាស់តែម្តង។ សូមឲ្យគាត់រៀបចំសំណួរឡើងវិញ កុំឲ្យនិយាយដោយគ្មានយោងទៅលើអ្វីឲ្យច្បាស់លាស់ ពីព្រោះថានៅទីនេះយើងទាំងអស់គ្នា ដូចជាស្តាប់សក្ខីកម្មហ្នឹង វាឮខុសៗគ្នាទាំងអស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីរៀបសំណួរម្តងទៀត ដើម្បីឲ្យសាក្សីបានឆ្លើយត្រឹមត្រូវ។

[១៣:៥៨:៣១]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** លោកស្រីថា ធ្វើការពេលយប់។ តើបានពន្លឺអ្វីដើម្បីលោកស្រីធ្វើការ?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ធ្វើនៅពេលយប់ មានភ្លើងបង្គោលគេធ្វើដាក់ភ្លើងអគ្គិសនីដែរ។ ធ្វើខែភ្លឺណាមើលឃើញត្រូវថ្ម ត្រូវអី ត្រូវជើង ត្រូវដៃ ធ្វើមិនកើតទេ ហ្នឹងខែភ្លឺហ្នឹង ដាក់ភ្លើងបង្គោលភ្លើង។

**ស៖** កាលពីព្រឹកមិញលោកស្រីបានមានប្រសាសន៍ថា មានអ្នកឈឺធ្ងន់ ឃើញទៅដេកពេទ្យ តែអត់ឃើញត្រឡប់មកវិញ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើក្រុមលោកស្រីមានអ្នកណាដែលឈឺធ្ងន់ដែរឬទេ?

**ឆ៖** នៅក្នុងក្រុមខ្ញុំ គ្មានអ្នកឈឺធ្ងន់ទេ មានតែអ្នកឈឺគ្រុនក្តៅ ហើយចុកពោះល្មមៗ ហើយអត់មានទេ អ្នកឈឺធ្ងន់។

**ស៖** ចុះលោកស្រីមានប្រសាសន៍ព្រឹកមិញថា មានអ្នកឈឺធ្ងន់អត់មានត្រឡប់មកវិញ។ តើចម្លើយរបស់លោកស្រីហ្នឹង ឮគេថា ឬក៏ជាចម្លើយដែលលោកស្រីបានឃើញផ្ទាល់? ហើយបើលោកស្រីបានឃើញផ្ទាល់ហ្នឹង តើអ្នកនោះមានឈ្មោះអ្វីដែរ?

[១៤:០០:៤៧]

**ឆ៖** ខ្ញុំមិនបានឃើញផ្ទាល់ទេ តែក្រុមគេមានឈឺធ្ងន់ តែគេយកទៅពេទ្យនៅឆ្ងាយ តែក្រុមខ្ញុំគ្មានទេ។ ខ្ញុំមិនស្គាល់ឈ្មោះទេ ឮតែគេថាដែរ ឈឺធ្ងន់ៗ គេបញ្ជូនទៅហើយ កន្លែងពេទ្យឆ្ងាយ។

**ស៖** ចុះហេតុអ្វីបានជាលោកស្រីដឹងថាអត់ឃើញគេត្រឡប់មកវិញ?

**ឆ៖** ទៅបាត់ មិនឃើញមកវិញ មិនឃើញមែន ថាម៉េច បើអត់ឃើញមែន។

**ស៖** លោកស្រីមានប្រសាសន៍ថា គេអត់ឲ្យមានទំនាក់ទំនងរវាងក្រុមមួយទៅក្រុមមួយ គឺគិតតែធ្វើការមិនមានទំនាក់ទំនងបានទេ។ អ៊ីចឹង ហេតុអីបានជាលោកស្រីដឹងថា អត់ដឹងអ្នកហ្នឹងត្រឡប់មកវិញ? អត់ឃើញអ្នកហ្នឹងត្រឡប់មកវិញ?

**ឆ៖** បើអត់ឃើញមានមកវិញមែន ឲ្យខ្ញុំថាម៉េច។

**ស៖** តើអ្នកហ្នឹងគាត់ឈ្មោះអីដែរ លោកស្រី?

**ឆ៖** ខ្ញុំភ្លេចឈ្មោះអស់ហើយ មិនដឹងជាឈ្មោះអីទេ វង្វេងអស់។

**ស៖** គាត់ស្រី ឬមួយក៏ប្រុស?

**ឆ៖** ភាគច្រើន ច្រើនតែស្រី។

**ស៖** ក្រុមដែលគាត់ធ្វើការហ្នឹងនៅចម្ងាយប៉ុន្មានពីក្រុមរបស់លោកស្រី?

**ឆ៖** ខ្ញុំមិនដឹងជាចម្ងាយប៉ុន្មានទេ ភ្លេចអស់ហើយ។

**ស៖** ដោយសារលោកស្រី គាត់(ឮមិនច្បាស់) ៧៥ លោកស្រីកើតនៅក្នុងភូមិត្រស់ហ្នឹង នៅឃុំបល្ល័ង្គ ហើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏លោកស្រីរស់ដដែល ហើយបច្ចុប្បន្នក៏លោកស្រីរស់នៅទីនោះដដែល។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់ពីការកត់សម្គាល់ឃើញរបស់លោកស្រី។ នៅពេលដែលមុនធ្វើទំនប់១មករានេះ តើប្រជាជនដែលនៅក្នុងតំបន់របស់លោកស្រីហ្នឹង គាត់ធ្វើស្រែហ្នឹង វាងាយស្រួល ឬក៏វាជួបឧបសគ្គអីដែរបាទ?

[១៤:០៤:៥៣]

**ឆ៖** នៅមុនពេលធ្វើទំនប់ហ្នឹង អ្នកស្រុកភូមិខ្ញុំហ្នឹង ខ្ញុំភ្លេចអស់ហើយ ដូចជាធ្វើស្រែប្រវាស់ដៃ។

**ស៖** មានទឹកសម្រាប់ធ្វើស្រែគ្រប់គ្រាន់ដែរឬទេ លោកស្រី?

**ឆ៖** ចាស មាន។

**ស៖** សំណួរខ្ញុំសួរមុនគេដែលមានទំនប់១មករាហ្នឹង តើប្រជាជនហ្នឹង គាត់មានទឹកធ្វើគ្រប់គ្រាន់ទេ? ហើយបើមានទឹក តើទឹកហ្នឹងបានមកពីណាដែរ?

**ឆ៖** ចាស មានទឹក មានហ្នឹងបានទឹកភ្លៀង ភ្លៀងមកតាំងពីកាលនុ៎ង វាសម្បូរទឹកភ្លៀង។

**ស៖** អ៊ីចឹងដែលជួបប្រទះឆ្នាំណាដែលមានការរាំងភ្លៀងដែរទេតាមការសង្កេតរបស់លោកស្រី?

**ឆ៖** ចាស មានឆ្នាំណាអត់ទឹកភ្លៀង ក៏ត្រូវស្កកខូចអស់ ស្វិតក្រៀមខូចអស់ខ្លះទៅណា ស្រែណាជ្រៅ ក៏នៅបានផ្លែទៅ។ ស្រូវស្រែណារាក់ ក៏ខូចខាតខ្លះទៅ។

**ស៖** ចុះបន្ទាប់ពីការធ្វើទំនប់១មករាហើយ តើប្រជាជនគាត់ធ្វើស្រែដោយពឹកផ្អែកលើទឹកភ្លៀងទៀត ឬមួយក៏គាត់ពឹងផ្អែកទៅលើទឹកទំនប់១មករា?

[១៤:០៧:២៧]

**ឆ៖** ចាស ប្រជាជនខ្លះក៏ធ្វើដោយទឹកទំនប់ទៅ ដែលធ្វើស្រែប្រាំងទៅ ខ្លះក៏គេមិនធ្វើទៅ គេធ្វើតែស្រែវស្សា។

**ស៖** តើលោកស្រីអាចដឹងបានទេ ប្រជាជនប៉ុន្មានស្រុកដែលប្រើប្រព័ន្ធធារាសាស្ត្រទំនប់១មករារហូតដល់បច្ចុប្បន្នហ្នឹងលោកស្រី?

**ឆ៖** ចាស ខ្ញុំមិនសូវដឹងដែរ ដឹងថាទៅខាងស្រុកបារាយណ៍។

**ស៖** ចុះចំពោះខាងស្រុកសន្ទុកវិញ តើគេប្រើប្រាស់ទឹកទំនប់១មករាដែរឬទេបាទ?

**ឆ៖** ចាស ខាងហ្នឹងក៏ប្រើទឹកទំនប់ហ្នឹងដែរ ខាងហ្នឹងពិសេសជាង -- ពិសេសខាងស្រុកសន្ទុកហ្នឹង ប្រើទឹកទំនប់ហ្នឹង។

**ស៖** តាមការកត់សម្គាល់របស់លោកស្រីបច្ចុប្បន្ននេះ តើប្រជាជនដែលគាត់ធ្វើស្រែហ្នឹង ដោយប្រើទឹកទំនប់ហ្នឹង គាត់ធ្វើបានប៉ុន្មានដងក្នុងមួយឆ្នាំដែរ បាទ?

**ឆ៖** ចាស គេធ្វើបានពីរដងក្នុងមួយឆ្នាំ ស្រែប្រាំង ហើយនិងស្រែវស្សា។

[១៤:០៩:៣៨]

**លោក លីវ សុវណ្ណា៖**

បាទ អរគុណលោកស្រីសាក្សី។ អរគុណ ខ្ញុំបាទសូមអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន អញ្ជើញមានសំណួរ!

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** ជម្រាបសួរលោកស្រី បាទ ខ្ញុំឈ្មោះ អាកទូរ វែកកែន ខ្ញុំជាមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំមានសំណួរតិចទេ ព្រោះថាសំណួរភាគច្រើន គឺគេសួរលោកស្រីអស់ហើយទៅហើយ។ អ៊ីចឹងខ្ញុំសួរខ្លីទេ។ សំណួរទី១ ទាក់ទងទៅនឹងកូនរបស់លោកស្រី គឺថាលោកស្រីនិយាយថាលោកស្រីមានកូនពីរនាក់ ដែលលោកស្រីអម្បាញ់មិញនេះប្រាប់កាលបរិច្ឆេទថា គាត់កើតនៅឆ្នាំ៨១មានតែមួយទេ។ តើជាកូនភ្លោះឬក៏យ៉ាងម៉េច? បើមិនអ៊ីចឹងទេ កាលបរិច្ឆេទមួយទៀតថ្ងៃខែឆ្នាំកំណើតកូនម្នាក់ទៀតនោះ កើតនៅពេលណាដែរ?

**លោកស្រី កង អ៊ុត៖**

**ឆ៖** ចាស ខ្ញុំមានកូនស្រីពីរ។ វង្វេងឆ្នាំ អត់បានៗមើល។ បើនិយាយរាប់តាមឆ្នាំខ្មែរយើងថាកើត -- មួយកើតឆ្នាំ--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ឆ្នាំរកា មួយឆ្នាំជូត មិនបានរាប់ឆ្នាំភ្លេចអស់ហើយ។

[១៤:១១:៣២]

**ស៖** បាទ សូមអរគុណ។ តើកូនស្រីរបស់លោកស្រីម្នាក់នុ៎ង កើតនៅក្នុងអំឡុងពេលរបបខ្មែរក្រហម គឺចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ឬក៏យ៉ាងណា?

**ឆ៖** កូនស្រីខ្ញុំកើតរំដោះរួចហើយ មិនដឹងឆ្នាំអីវង្វេង ឆ្នាំរកាមិនដឹងជាត្រូវឆ្នាំអី។ ឆ្នាំរកាមួយឆ្នាំជូតមួយ។

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំយល់ហើយ។ ឥឡូវខ្ញុំចូលទៅនិយាយអំពីប្រធានបទថ្មីមួយទៀត តើមុនឆ្នាំ១៩៧៥ លោកស្រីព្យាបាលខ្លួនយ៉ាងដូចម្តេចដែរនៅពេលដែលលោកស្រីឈឺ? តើពេលនោះៗ លោកស្រីប្រើថ្នាំខ្មែរ ឬលោកស្រីទៅមន្ទីរពេទ្យ?

**ឆ៖** កាលឆ្នាំនុ៎ង ខ្ញុំមិនសូវជាឈឺទេ ល្មមៗ ខ្ញុំផឹកតែថ្នាំខ្មែរ រកផឹកទៅ។

**ស៖** ហើយនៅអ្នកជិតខាងរបស់លោកស្រីហ្នឹង នៅក្នុងភូមិលោកស្រីហ្នឹង មុនឆ្នាំ១៩៧៥ ពេលដែលគេឈឺអ៊ីចឹង តើគេរកថ្នាំខ្មែរ ឬក៏គេទៅមន្ទីរពេទ្យ?

[១៤:១៣:៤៥]

**ឆ៖** ចាស មិនសូវមានពេទ្យទេ នៅនឹងហ្នឹងពេទ្យនៅឆ្ងាយ។ នៅភូមិខ្ញុំពីមុនគ្មានពេទ្យជិតទេ គេផឹកតែថ្នាំខ្មែរហ្នឹងឯង។ តែឈឺខ្លាំងបានមកពេទ្យឆ្ងាយៗ ដល់ពេទ្យស្រុក។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេថា មន្ទីរស្រុកហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរស្រុកឆ្ងាយនៅពី -- មកពីផ្ទះខ្ញុំមកប្រហែលជា៣, ៤, ៥គីឡូ។

**ស៖** នៅមុខអង្គជំនុំជម្រះនេះមានសាក្សីម្នាក់មកផ្ដល់សក្ខីកម្មឈ្មោះ អ៊ុត សេង គឺឯកសារ E1/909.1។ គឺនៅថ្ងៃទី០៣ មិថុនា ២០១៥ ម៉ោង១០:៤៥:៣៥វិនាទី គេបានសួរសំណួរទៅគាត់ទាក់ទងទៅនឹងអង្គភាពពេទ្យចល័ត ដែលទៅការដ្ឋានទំនប់១មករា។ បាទ សំណួរនិងចម្លើយដែលគេសួរគាត់ដូចតទៅនេះ សូមដកស្រង់៖ "អ្នកដែលមកពីកងពេទ្យចល័តនេះមកទំនប់១មករា ដើម្បីចាក់ថ្នាំ ឬយ៉ាងណា? ចម្លើយ៖ អង្គភាពពេទ្យចល័តហ្នឹងគឺនៅក្រោម -- គឺនៅកន្លែងមួយហើយអ្នកដែលមានអ្នកឈឺអីហ្នឹងទៅឲ្យគេចាក់ថ្នាំ។ អាហ្នឹង ខ្ញុំដឹងត្រឹមតែប៉ុណ្ណឹង ឈឺទៅឲ្យគេចាក់ថ្នាំនៅនឹងរោងហ្នឹងទៅ។ សំណួរ៖ តើគេមានសម្លាប់មេរោគសេរ៉ាំងអីទេមុននឹងចាក់ថ្នាំ? ចម្លើយគាត់ឆ្លើយ៖ បាទ។ សំណួរ៖ តើគេសម្លាប់មេរោគយ៉ាងម៉េច? ចម្លើយរបស់គាត់ថា៖ គេស្ងោរមុននឹងប្រើប្រាស់សេរ៉ាំងទាំងអស់នោះ"។ បាទ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើនៅក្នុងកងរបស់លោកស្រីនេះ លោកស្រីមានធ្លាប់ទៅសុំឲ្យគេព្យាបាលដែរឬទេ ពេទ្យចល័តនេះមានដែលទៅសុំឲ្យពេទ្យចល័តនេះព្យាបាលដែរឬទេ ពេលដែលលោកស្រីឈឺនៅទំនប់១មករាហ្នឹង?

[១៤:១៧:១៤]

**ឆ៖** ចាស ខ្ញុំមិនដែលទៅទេ ខ្ញុំមិនដែលឈឺអង្កាល់នោះ នៅក្មេងមិនសូវជាឈឺទេ។

**ស៖** បាទ ខ្ញុំសូមអរគុណ។ តើលោកស្រី -- លោកស្រីមិនដែលធ្លាប់ឮគេនិយាយអំពីពេទ្យចល័តហ្នឹងនៅការដ្ឋានទេ ឬក៏យ៉ាងណា?

**ឆ៖** ចាស ខ្ញុំអត់ដែលទេ អត់ដែលឮទេ។

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំសូមឲ្យលោកស្រីជួយបំភ្លឺចំណុចមួយដែលលោកស្រីបានឆ្លើយអម្បាញ់មិញនេះ។ សូម ខ្ញុំសូមឲ្យលោកស្រីជួយបំភ្លឺ គឺទាក់ទងទៅនឹងថ្ងៃសម្រាករបស់លោកស្រី។ កាលពីព្រឹកមិញនៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួរនោះ លោកស្រីបាននិយាយថា នៅថ្ងៃសម្រាកទាំងអស់នោះលោកស្រីទៅជួបប្ដីរបស់លោកស្រី ហើយរសៀលនេះហ្នឹងលោកស្រីហាក់ដូចចង់

និយាយថា លោកស្រីបានចេញពីទំនប់ -- ឈប់ធ្វើការនៅទំនប់១មករានេះ ក្រោយពេលដែលរៀបការហើយបានបន្តិច។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់បន្តិចថា លោកស្រីបានសម្រាកជាមួយប្តីលោកស្រីដែរឬទេ? ហើយលោកនៅតែធ្វើការទំនប់១មករាហ្នឹងដដែល ឬក៏គេចាត់តាំងឲ្យលោកស្រីទៅធ្វើការកន្លែងផ្សេង? សូមលោកស្រីចូលរួមបំភ្លឺចំណុចនេះបន្តិចបានទេ?

[១៤:១៩:០៤]

**ឆ៖** ចាស ខ្ញុំកាលនោះ បានគេឲ្យសម្រាកក៏មកជួបប្តី ហើយក៏រួចពីហ្នឹងក៏ទៅធ្វើវិញ ហើយបានបន្តិចក៏គេដកមកឲ្យទៅធ្វើតាមមុខព្រួញ ដូចជាស្ទូងស្រែ ស្ទូងអី ហើយឈប់ធ្វើទំនប់ទៅ។

**ស៖** ហើយចំណែកឯប្តីលោកស្រីវិញ គាត់នៅតែបន្តធ្វើការនៅទំនប់១មករាហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** គាត់អត់ធ្វើទេ ទំនប់។ ប្តីខ្ញុំគាត់គេឲ្យខាងធ្វើស្រែ ភ្ជួរស្រែ ធ្វើស្រែប្រាំង។

**ស៖** តើនៅពេលដែលលោកស្រីបានជួបគាត់ពេលសម្រាករាល់១០ថ្ងៃម្តងហ្នឹង តើលោកស្រីជួបគាត់ហ្នឹង ទៅជួបគាត់ហ្នឹងនៅភូមិជាមួយគ្នាហ្នឹង ឬក៏នៅឯណាផ្សេង?

**ឆ៖** នៅឯផ្ទះខ្ញុំ ផ្ទះនៅនឹងភូមិត្រស់។

**ស៖** នៅភូមិកំណើតរបស់លោកស្រីហ្នឹង តើលោកស្រីមានមុងដែរឬទេ?

**ឆ៖** ចាស កាលនោះគ្មានទេមុង។

**ស៖** បន្ទាប់មកទៀតនៅពេលដែលលោកស្រីត្រូវបានគេចាត់តាំងឲ្យធ្វើស្រែនោះ ក្រោយពីបានធ្វើការនៅទំនប់ ១មករាហើយ។ អ៊ីចឹងលោកស្រីលែងជួបប្តីលោកស្រីទៀតហើយ ឬក៏នៅពេលដែលគេឲ្យទៅធ្វើស្រែហ្នឹង គឺលោកស្រីនៅតែបន្តទៅជួបប្តីលោកស្រីជាទៀងទាត់?

**ឆ៖** ចាស គេនៅតែឲ្យទៅជួបហ្នឹងឯង យូរៗទៅជួបម្តងទៅ។

**លោក អាកទូរ វែកកែន៖**

បាទ លោកស្រីសាក្សី ខ្ញុំសួរចប់ហើយ។ សូមអរគុណលោកប្រធានខ្ញុំអស់សំណួរហើយ។

[១៤:២២:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

សវនាការស្តាប់សក្ខីកម្មសាក្សី កង អ៊ុត ដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះអរគុណលោកស្រីកង អ៊ុត ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈ

ជាសាក្សីក្នុងរយៈពេលពេញមួយថ្ងៃនេះ។ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចចូលរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកស្រី បានដល់ទីបញ្ចប់ហើយ។ សូមលោកស្រីមានសំណាងល្អ មានសេចក្តីសុខចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅវិញ។

ដំណើរការសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

អង្គជំនុំជម្រះសូមជម្រាបជូនដល់សាធារណជនផងដែរថា ចាប់ពីថ្ងៃចន្ទ ទី២៩ ខែមិថុនា ឆ្នាំ២០១៥ សប្តាហ៍ក្រោយរហូតដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ អង្គជំនុំជម្រះមិនធ្វើសវនាការនៅថ្ងៃទាំងនោះទេ។ សវនាការដែលនឹងចាប់ផ្តើមធ្វើឡើងវិញនៅថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០១៥ ដូចតទៅ។ អង្គជំនុំជម្រះនឹងធ្វើស្តាប់សក្ខីកម្ម សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអង្គហេតុទំនប់ត្រពាំងថ្ម។ ចំពោះលំដាប់លំដោយសាក្សីដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអង្គហេតុទំនប់ត្រពាំងថ្ម អង្គជំនុំជម្រះបានជម្រាបជូនភាគីតាមរយៈអ៊ីម៉ែលរួចហើយ។ ដូច្នេះសូមភាគី និងសាធារណជនជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៤:២៥ នាទី)*